# ការសំភាសន៍របស់អ្នកមីង ឆេង វី

កៈ អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ឆេង វី

## ការសង្ខេបរបស់អ្នកមីង ឆេង វី

អ្នកមីងឆេង វី គាត់ជាងអ្នកខេត្តកណ្តាលសព្វថ្ងៃគាត់រស់នៅជាមួយស្វាមីក្រោយនឹងកូនស្វាមីគាត់មុនបានស្លាប់ទឹមគាត់មានស្វាមីក្រោយទៀត!!រាល់ថ្ងៃអ្នកមីងជាស្ត្រីមេផ្ទះហើយនៅមើលថៃកូន បងប្អូនរបស់គាត់ម្នាក់បានស្លាប់ហើយឪពុកម្តាយរបស់គាត់ក៏បានស្លាប់ដែរ ។ ឪពុករបស់អ្នកមីងបានស្លាប់កាលពេលជំនាន់ប៉ុល ពត ពួកប៉ុលពតបានវ៉ៃគាត់រហូតទាល់តែឈឺស្លាប់ហើយម្តាគាត់ក៏បានរៀបជាមួយស្វាមីក្រោយតែមីងបានប្រាប់ថាឪពុកក្រោយគាត់គឺជាមនុស្សល្អ។
អ្នកមីងបានប្រាប់ថាម្តាយគាត់គឺជាមនុស្សល្អហើយស្លូតបូតចូលចិត្តជួយគេហើយគាត់ជាអ្នកកាន់សីល១០
តែដោយសារគាត់មានជំងឺទើបគាត់បានស្លាប់ទៅ។ពេលមុនអ្នកមីងធ្លាប់ធ្វើការដែរនៅខេត្តរតនៈគិរីព្រោះគាត់ចង់មានប្រាក់កាសខ្លួនឯងនឹងសំរាប់ក្រុមគ្រួសារ
។សព្វថ្ងៃអ្នកមីងពុំមានជីវភាពមានប៉ុន្មានទេតែគាត់រស់នៅដោយសុភមង្គលជាមួយគ្រួសារគាត់។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលបានអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវិតអ្នកមីងនៅក្នុងថ្ងៃនេះហើយពួកយើងសំភាសន៍គឺនៅក្នុងខែឧសភាឆ្នាំ២០១៦ (ច្រឡំសំភាសន៍ហ្នឹងគឺឆ្នាំ២០១៨)។ ពួកយើងសំភាសន៍គឺនៅក្នុងភូមិភូមិអីគេដែរអ្នកមីង?

ខៈ ភូមិញ៉ុមហោ?

កៈ ចាំ!!

ខ៖ គេហៅភូមិព្រៃកហូរ ពេលមុនគេហៅដំណាក់សង្កែទេ ដល់ពេលញុំមមួយកាត់ចុះត្រឹមពីស្ពានមករហូតមកដល់ត្រវេសគឺសុទ្ធតែនៅព្រៃកហូរទាំងអស់!!

ក៖ ហុឺឥឡូវនេះគេហៅភូមិព្រៃកហូរហើយហោ?

ខ៖ចាំ!!

ក៖ ហុឺ!!

ខ៖ ចាំ!!ក៖អ៊ីចឹងអានេះឥលូវនៅក្នុងភូមិព្រៃកហូរលិចទេហី?

ខ៖ ចាំ!!នៅភូមិព្រៃកហូរ មិនដឹងសង្កាត់ប៉ុន្មានទេញុំមមិនដឹងទេ!!ភូមិព្រៃកហូរ ពូមួយពូហ្នឹងឈ្មោះអ៊ីពូអ៊ីនេះហ្នឹងប្រធានភូមិដែរហើយពូអីមួយភ្នែកស្រឡូវ អាផ្លូវចុះទៅកន្លែងបន្ទាយនេះនោះណាស់!!

ក៖ ភ្នែកស្រឡូវហោ?

ខ៖ ចាំ ពូហ្នឹងទ្រង់ធាត់ខ្មៅ ទ្រង់ភ្នែកស្រលៀងហាំ!!

ក៖ ចាំចាំ!!

ខ៖ ចាំហ្នឹង ហ្នឹងប្រធានភូមិញុំមហ្នឹងហាំ!!

ក៖ ហ្ហូ!!

ខ៖ហ្នឹងហើយ!!

ក៖ អញ្ចឹងនៅនេះនៅក្នុងភូមិព្រៃកហូរលិច ឃុំព្រៃកហូរហាសង្កាត់ព្រៃកហូរ !!

ខ៖ ហ្នឹងហើយើ!!

ក៖ ក្រុងតាខ្មៅ ខេត្តកណ្តាលនៅឡើយទេអ៊ីចឹង!!

ខ៖ ហ្នឹងហើយសង្កាត់ព្រៃកហូរហ្នឹងអ៊ីចឹង!!ព្រៃកហូរខាងលិច !

កៈចាំហ្នឹងហើយ!!

ខៈ មុននៅដំណាក់សង្កែតើតែឥឡូវវាបែកគ្នាហើយ បែកគ្នាអស់ហើយ!!

កៈហ្អូ!!

ខៈ ដល់ពេលញ៉ុមធ្វើបោះឆ្នោតបោះអីបោះសាលាព្រែកហូរតើនៅវត្តហ្នឹងតើវត្តគោពីរហ្នឹង។

កៈ ហ្នឹងហើយ អ៊ីចឹងពេលមុននៅទីនេះគេហៅភូមិដំណាក់សង្កែរហ្នឹងហើយមែនទេ?

ខៈ ហ្នឹងហើយដំណាក់សង្កែ!!

កៈ តែឥឡូវគេដូរមកជាភូមិព្រែកហូរវិញហើយ!!

ខៈ ហ្នឹងហើយ!!

កៈហ្អូ!!

ខៈត្រឹមហ្នឹងចុះទៅក្រោមគេហៅចុះសង្កាត់ព្រែកហូរទាំងអស់!!ហើយពីត្រឹមហ្នឹងទៅអញ្ចេះអាហ្នឹងដំណាក់សង្កែ!!

កៈហ្អូ!!

ខៈ ដំណាក់សង្កែខេត្តកណ្តាល ខេត្តកណ្តាលទៅកន្លែងទៅប្រធានភូមិគេគេបោះឆ្នោតនៅប្រធានភូមិគេនៅសាលាឃុំណេះ!!

កៈចាំ!!

ខៈ ចាំ!!

កៈ ចាំតាមពិតនេះហាមីងនៅជិតនេះតើខាងនោះនៅភ្នំពេញមីងមែនទេ យើងនៅជិតភ្នំពេញខ្លាំង!!

ខៈ ចាំចាំ!!

កៈ អញ្ចឹងអ្នកមីងសំរាប់ឈ្មោះអ្នកមីងពេញអ្នកមីងឈ្មោះអីគេដែរ?

ខ៖ចាំ?

ក៖ ឈ្មោះហា?

ខ៖ ញ៉ុមហោ?

ក៖ ចាំ!!

ខ៖ វី!!

ក៖ វី?

ខ៖ ចាំ!

ក៖ត្រកូលមីងអីគេដែរ?

ខ៖ នាមត្រកូលញ៉ុម នេះឪពុកម្ដាយញ៉ុមស្លាប់អស់ហើយ!!

ក៖ចាំ!!

ខ៖គាត់ស្លាប់អស់ហើយ!!

ក៖ហ្នឹងហើយ តែពេលឈ្មោះអ្នកមីង!!

ខ៖ តែពេលឪពុកញ៉ុមពីមុនឈ្មោះស៊ឹម អឿន!

ក៖ចាំ!

ខ៖តែពេលបានពុកក្រោយម៉ែញ៉ុមបានប្ដីគាត់តាំងពីពេលជំនាន់អាពតឥឡូវ ឆេង អឿន!!ហើយប្ដីពេលមុនម៉ែញ៉ុមស្លាប់បាត់ហើយតែនៅឪពុកចុង!!

ក៖ ឪពុកបង្កើតហា ឪពុកបង្កើតឈ្មោះអី?

ខ៖ ឪពុកបង្កើតឈ្មោះស៊ឹម!!

ក៖ ស៊ឹម?

ខ៖ចាំ!!

ក៖ អញ្ចឹងអ្នកមីងឈ្មោះស៊ឹម រីហើយមែនទេ?

ខ៖ចាំ!!

ក៖ អញ្ចឹងស៊ឹម រី ច្បាស់អត់?

ខ៖ចាំ!!

ក៖ចាំអ៊ីចឹងអ្នកមីងស៊ឹមរី!!

ខ៖ ស៊ឹម រី ប៉ុន្ដែញ៉ុមធ្វើអីៗក៏ដោយខ្ញុំដាក់តែឈ្មោះឆេងទេ ឆេង រីទេ!!

ក៖ឆេង រីទេហោ?

ខ៖ចាំ!!

ក៖ តែហ្នឹងឪពុកចុងទេហោ?

ខ៖ចាំ!!ហ្នឹងហើយញ៉ុមដាក់ឪពុកចុង អ៊ីចឹងបានបងខ្ញុំបង្កើតបងខ្ញុំបង្អស់ថាហ៊ីអារីឯងធ្វើអីៗម៉េចចាំបាច់ដាក់ឈ្មោះឆេអអញ្ចឹង?ដាក់ឈ្មោះស៊ឹម ដាក់ឈ្មោះឪពុកឯងបង្កើតអត់ដាក់ទេ!!អ៊ីចឹងហិ បងញ៉ុមទាំងអស់សុទ្ធតែដាក់ឈ្មោះស៊ឹមទាំងអស់ ហាឆេង មានតែបងថ្លៃញ៉ុមមួយនៅនេះនៅដំណាក់សង្កែរនេះគាត់ដាក់ឈ្មោះស៊ឹម គាត់ថាដាក់ឈ្មោះឪពុកញ៉ុមពីមុនណាស់!!ក៖ចាំ!!

ខ៖ ដល់ពេលបានពុកក្រោយញ៉ុមដាក់ឈ្មោះឆេង ឆេង ហ្នឹង!!ឆេង រី ឆេង រី បងញ៉ុមណោះឆេងទាំងអស់ ឆេង អាត ឆេង រ៉ី ទាំងអស់!!

ក៖ហ្អ!!

ខ៖ចាំ!!

ក៖អូខេ!!អ៊ីចឹងប៉ុន្ដែឪពុកបង្កើតឈ្មោះស៊ឹមទេ?

ខ៖ចាំ!!

ក៖ អញ្ជឹងយកឈ្មោះឪពុកចុងអ្នកដាក់ត្រកូលហ្នឹងទេ!!

ខ៖ចាំ!!

ក៖ តែឪពុកមែនទែនឈ្មោះស៊ឹម!!

ខ៖ចាំ!!

ក៖ អ្នកមីងសព្វថ្ងៃមានអាយុប៉ុន្មាន៥០ឆ្នាំហើប្រាប់ញ៉ុមពេលមិញ?

ខ៖ ចាំ?ញ៉ុមដូចអត់សូវចាំដែរ មីអូនហាអត់ចាំខែឆ្នាំ!!

ក៖ ចាំអាយុ អត់ចាំអាយុខ្លួនឯងទេចុះ?

ខ៖ អត់ វាអត់ចាំដែរហ្នឹងហាំ វាអារឿងអញ្ជឹងៗវាញ៉ុមអត់សូវយកចិត្តទុកដាក់។

ក៖ហ្វ៎!!

ខ៖អត់ចាំរបស់ខ្លួនឯងប៉ុន្មានៗអត់ចាំ!

ក៖អត់ចាំអាយុខ្លួនឯង!!

ខ៖ ចាំ ប៉ុន្តែកូនញ៉ុមផងញ៉ុមអត់សូវចាំហិ!!

ក៖ចាំ!!

ខ៖
កូនញ៉ុមអត់ដឹងវាកើតថ្ងៃណាថ្ងៃណាឆ្នាំណាឆ្នាំណាញ៉ុមអត់ចាំផងហិ!!ញ៉ុមនៅប្តីញ៉ុមប្តីញ៉ុមសុទ្ធតែកត់ដាក់ក្រដាសតែដល់ពេលប្តីញ៉ុមស្លាប់បាត់ទៅក្រដាសហ្នឹងអត់មាន ដល់ពេលគេសួររកសារេរើធ្វើអីៗយកសៀវភៅគ្រួសារយកទៅអោយគេមើលទេ!!

ក៖ចាំ!

ខ៖ញ៉ុមអត់សូវចាំហាព្រោះញ៉ុមអត់សូវចេះអក្សរព្រោះញ៉ុមអត់សូវចូលចិត្តទុកដាក់អារឿងអញ្ចឹងៗ!!

ក៖ចាំ!!

ខ៖
ញ៉ុមយកចិត្តទុកដាក់តែរបស់ណាដែររកស៊ីអញ្ចឹងៗទៅមានអីៗនៅក្នុងផ្ទះរាល់ថ្ងៃអញ្ចឹងណាស់!!ដល់ពេលដល់អារបស់កូនចៅកើតនៅថ្ងៃខែណាឆ្នាំណាអីចឹងញ៉ុមអត់សូវយកចិត្តទុកដាក់!!

ក៖ ហ្នូអីចឹងហេ?

ខ៖ចាំ!!

ក៖ អញ្ចឹងអ្នកមីងភ្លេចច្រើនណោះអ្នកមីងណោះ?

ខ៖ចាំ!!

ក៖ហើយណាមួយអត់ខ្វល់ទៀតអ្នកមីងក៏ភ្លេចទៅ !!

ខ៖ ចាំហ្នឹងហើយ!!

ក៖
តែមិញដូចជាប្រាប់ញ៉ុមថាអាយុ៥០មែនទេ?ស្មានៗខ្លួនឯងអីចឹងទៅហេ?មីងកើតទាន់ជំនាន់ប៉ុល ពតមែនទេ?

ខ៖ អត់ទេញ៉ុមការកាលការហ្នឹងញ៉ុមអត់ទាន់ពេញអាយុទេណាស់!!តែពេលញ៉ុមការហ្នឹងញ៉ុមនៅពោធិ៍ចិនតុង តែដល់ពេលហើយហើយគេស្រលាញ់ តែម៉ែញ៉ុមគេសុំធ្វើកូនធម៌ តែដល់ពេលហើយញ៉ុមនៅប្រហែលជាខ្ទង់ទូចៗដែរញ៉ុមប្រហែលជានៅ១២ឆ្នាំហាំ!!តែញ៉ុមនៅទូចតែញ៉ុមចេះដឹងហាំ!!ញ៉ុមចេះដឹងញ៉ុមចេះធ្វើខ្លួនញ៉ុមចេះសំអាតខ្លួនឯងញ៉ុមចេះដឹងញ៉ុមសក់ត្រឹមណាត្រឹមណីដល់ពេលហើយញ៉ុមដាំបាយអីអោយគាត់អីចឹង តែដល់ពេលយូរៗគាត់ចងង់មកស្រលាញ់ញ៉ុមប៉ុន្តែគាត់ប្រាប់ម៉ែញ៉ុម

ពេលជំនាន់ហ្នឹងគាត់ចង់នាំទៅកំពត ញ៉ុមអត់ចង់ទៅទេកំពត ថាញ៉ុមនៅលក់អីនៅសាលារៀន១០០ខ្នងនេះញ៉ុមធ្វើអីម៉ែញ៉ុមទិញអីៗអោយយកអោយមកលក់ នំអាកោរផង នំបាញ់ចំនឿកផងនំបំពង់ផងញ៉ុមលក់គាត់អត់អោយញ៉ុមលក់ទេម៉ែឯងអោយលក់អញ្ចឹងសិស្សសាលាលេងសើចជាមួយគាត់ច្រើនណាស់លេងសើចជាមួយនឹងអាមុំ!!ហៅញ៉ុមអីចឹងហា៎ ហៅញ៉ុមអាមុំ លេងសើចជាមួយអាមុំច្រើនណាស់ញ៉ុមអត់ចូលចិត្តទេ!!ប្រយត្ន័ញ៉ុមដៃដល់ប្រយត្ន័ញ៉ុមឃើញទះងាប់ហា៎!!ហើយម៉ែញ៉ុមថាអញ្ចេកហ៊ីកូនអោយវាលក់ទៅព្រោះវានៅក្មេងវាលក់ដាច់ម៉ែវាចាស់ហើយវាលក់អត់ដាច់ទេកូន!!ថាអញ្ចឹងហាញ៉ុមប្រាប់មីអូនឯងហើយដល់ហើយគាត់ធ្វើការធំហា គាត់ធ្វើការធំមានកាំភ្លើងខ្លី នៅតំបន់៣ហ្ន៎ សាលាតំបន់៣នៅពោធិ៍ចិនតុងហ្នឹងហា៎!!

ក៖ អ្នកណាគេអ្នកណាគេ?

ខ៖ ប្ដីញ៉ុមមុនហ្នឹងហា៎ ចា៎!!

ក៖ហ្ន៎!!

ខ៖ហើយដល់ហើយគាត់ថាគាត់ទៅតែមួយភ្លែតទេ
ទៅដល់ហើយគាត់អោយកូនចៅគាត់ឈរតំរង់ជួរសុទ្ធតែតំរង់ជួរហើយគាត់ត្រលប់មកវិញអោយតែសិស្សសាលាចេញលេង
មួយព្រឹកចេញពីរសារគាត់មកមើលតែម៉ោង៧ម៉ោង៨ចេញលេងម្ដងទៀតគាត់មកទៀតហើយ គាត់អត់មានទេ គាត់នៅអង្គុយអញ្ចឹងហិហើយសិស្សសាលាមកពេញណាពេញណី ហើយញ៉ុមលក់ដាច់អើយដាច់អូនណ្ហើយនំហូរហែរដាច់ណាស់
មានអាលក់ដាច់ដូចខ្ញុំទេថាខ្ញុំលក់ដាច់ណាស់។

ក៖ នៅសាលា១០០ខ្នងហោ?

ខ៖ ចា៎!!ហ្អែងថាសិស្សសាលាលេងសើចច្រើនណាស់អត់អោយអាមុំលក់ទេម៉ែឯងលក់ទៅ !! ម៉ែថាអត់ទេអោយវាលក់ទៅវាក្មេង!!

ក៖ គាត់ប្រចណ្ឌ័ហោ?

ខ៖ចា៎!!ថាម៉ែចាស់ហើយលក់អត់ដាច់ដូចក្មេង!!ចុះម៉ែឯងមមើលលេងសើចច្រើន!!
ចុះវាធម្មតាអ្នកលក់អ្នកទីញត្រូវតែលេងសើចគ្នាហើយកូនកុំប្រកាន់អី

តែលេងសើចបានលក់ដាច់
អាទិញគ្នាទិញស៊ីអ្នកលក់មុខក្រញូវអញ្ចឹងលក់អត់ដាច់ទេម៉ែញ៉ុមថាអញ្ចឹងហាំ
បានជាយូរៗៗស្រលាញ់ខ្ញុំ ខ្ញុំអត់ទាន់ពេញអាយុផងញ៉ុមបានការ
ការញ៉ុមប្រាប់មីអូនឯងតាមត្រង់ការបានប្រហែលមួយអាទិត្យញ៉ុមចាប់ផ្តើមចាប់មានកូនតទៅរ
ហូតហិបានញ៉ុមមានកូនហ្នឹង!!

កៈ ការអាយុប៉ុន្មាន?

ខៈ ការអាយុទឹម១៧ហ្នឹងហេ!!

កៈចាំអ៊ីចឹងមានកូនតាំងពីអាយុ១២?

ខៈ ចាំហ្នឹង!!

កៈ ការបានមួយអាទិត្យដឹងខ្លួនមានកូនម៉ង?

ខៈ
ចាំហ្នឹង!!អញ្ចឹងបានថាតឡូវបានញ៉ុមចាស់ទឹមតែអាយុ៥០ហើយហ្នឹងថាញ៉ុមចាញ់គេហាថាគេ
ចាញ់ញ៉ុមទៀតគេអាយុគេក្មេងជាងញ៉ុមទៀតគេចាស់ជាងញ៉ុមទៅទៀតថាញ៉ុមចាំសាច់
ថាអញ្ចឹងហិ!!

កៈ សាច់ចាំ!!

ខៈចាំ!!

កៈហ្នឹងហើយ!!

ខៈ
តែបើញ៉ុមនៅស្រណុកវិញហាំញ៉ុមនៅមានស៊ីមានចាយមានលុយពេញៗដៃញ៉ុមហូបហាមួយ
ពេលស៊ី៣ ៤ ៥មុខអីវ៉ាន់អីចឹតងហាំញ៉ុមមិនដឹងសាច់ស្អាតយ៉ាងណាទេ!!

កៈ តែមីងតឡូវក៏មិនធម្មតាដែរ៥០មែន!!

ខ៖ អញ្ចឹងបានថា!!គេប្អូនញ៉ុមផងណាស់ ញ៉ុមអាយុ៥០ គេទឹមតែ១៧ ១៨ ចាស់ជាងញ៉ុមទៀត!!

ក៖ចាំ!!

ខ៖ចាំហ្នឹងហើយ!!

ក៖ ចាំអញ្ចឹងទទួលបានពត៌មានអ្នកមីងថាអាយុអ្នកមីង៥០ឆ្នាំ!!

ខ៖ចាំចាំ!!

ក៖ ចាំអញ្ចឹងអ្នកមីងសំរាប់អ្នកមីងកើតឆ្នាំខ្មែរអ្នកមីងកើតឆ្នាំសត្វអីគេវិញ?

ខ៖ ញ៉ុមការទឹមតែបែកលន់ នល់ហើយអូន!!

ក៖ និយាយថាឆ្នាំសត្វខ្មែរហាំ!!

ខ៖ចាំ?

ក៖ ជូត ឆ្លូវ ខាល ថោះអីវ៉ាន់ហ្នុំអ្នកមីងចាំទេថាកើតឆ្នាំសត្វអីគេ?

ខ៖ ហ៊ឺអត់សូវចាំ បានថាបែកលន់ នល់ភ្លាមបានស្រុកស្រួលប្រួលញ៉ុមចាប់ផ្តើមការ ការហ្នឹងការនៅស្រុកម៉ែក្មេកញ៉ុមនៅកំពតអត់មានរបាំអីទេ
មានតែយីកេអត់ឲទាន់មានបាសអត់ទាន់អ្នកណាគេមានអីមានអីទេ មានតែលេងស្គរ ស្គរយីកេទេ កាលហ្នឹងហាំគ្រាន់តែបែកលន់ នល់បានស្រុកស្រួលប្រួលញ៉ុមចាប់ផ្តើមការហិ!!ការហ្នឹងញ៉ុមអត់ទាន់បានសប្បាយផងញ៉ុមថាអញ្ចេកអីទេម៉ែចាប់ខ្ញុំការ
ញ៉ុមថាម៉ែស្រលាញ់ម៉ែឯងទៅញ៉ុមស្រលាញ់ញ៉ុមវិញញ៉ុមថាអញ្ចឹងហាំ!!

ក៖ហ៊ឹ!!

ខ៖ ញ៉ុមអត់ទាន់បានដើរលេងពេញសប្បាយពេញរូបពេញរាងញ៉ុមផងទេអោយខ្ញុំការមានប្តី!!

ក៖ អីយ៉ាស់!! អញ្ចឹងមីងឆ្នាំខ្មែរខ្លួនឯងមីងអត់ចាំទេ?

ខ៖  ញ៉ុមអត់ចាំព្រោះញ៉ុមនៅតូចតាចញ៉ុមអត់សួរចាំព្រោះអីញ៉ុមកាលការញ៉ុមទឹមតែបែកលន់នល់ហើយយើងមានចាំអីឯងបើយើងអត់សួរចេះអក្សរអត់សួរចេះទុកដាក់អាអញ្ចឹងៗហាំ!!

ក៖ ចាំ!! ហើយចុះពេលអីវ៉ាន់ប្ដីមីងសួរមីងប្រាប់ថាមីងប្រាប់គាត់ថាមីងឆ្នាំអីគេអត់?

ខ៖ ប្ដីខ្ញុំត្រូវបងខ្ញុំ។

ក៖តែប្ដីមានដែលសួរមីងថាមីងកើតឆ្នាំជូត ឆ្លូវ ខាល ថោះ អីនោះ? មានដែលសួរទេ?

ខ៖       ចុះបើគាត់ញ៉ុមចាប់បានកូនពីរគាត់ចាប់ផ្ដើមស្លាប់ដែរ!!ស្លាប់ទៅចាំញ៉ុមបានមានកូន២កូន៣គាត់ចាប់ផ្ដើមស្លាប់។

ក៖ចាំ!!

ខ៖គាត់ស្លាប់ហ្នឹងគាត់ហូបកង្កែបគាត់មានធ្វើអី   គាត់អត់មានឈឺអត់មានអីទេ   គាត់មានពីសហូបកង្កែប គ្រាន់តែហូបយប់ហ្នឹងស្លាប់យប់ហ្នឹងដែរ។

ក៖ហ្ន៎អាសត្វអញ្ចឹងៗហោ!!

ខ៖ តែពេលហ្នឹងញ៉ុមទឹមតែបានកូន៣ទេណាស់!!

ក៖ចាំ!!អ៊ីចឹងរាល់ថ្ងៃមីងដឹងថាខ្លួនឯងអាយុ៥០ឆ្នាំនៅក្នុងឆ្នាំ២០១៨
អ៊ីចឹងប្រហែលជាកូនចៅជំនាន់ក្រោយបើចង់ដឹងថាអ្នកមីងកើតឆ្នាំណាគាត់ដកតាមឆ្នាំហ្នឹងទៅគាត់ដឹងហើយ!!

ខ៖ អញ្ចឹង!!

ក៖ មីងមានទីកន្លែងកំណើតនៅឯណាដែរ មានទីកន្លែងកំណើតនៅខេត្តណាវិញ?

ខ៖ ខេត្តណាញ៉ុមភ្លេចហើយ!!ញ៉ុមអត់សួរចាំម៉ង វាអត់ចាំ!!

ក៖ មីងកើតមកខេត្តនៅណាវិញ?កំពត?

ខ៖ ញ៉ុមកើតនៅជំណាក់សង្កែ!!

ក៖ ហ្ន៎កើតនៅនេះទេអញ្ចឹងហោ?

ខ៖ ចា៎!!ដំណាក់សង្កែ។

ក៖ ខេត្តកណ្តាល!!

ខ៖ ដំណាក់សង្កែរហ្នឹង!!

ក៖ ហ្នឹងហើយភូមិដំណាក់សង្កែរហ្នឹង!!

ខ៖ ចា៎ញ៉ុមកើតនៅហ្នឹងទាំងអស់ បងប្អូនកូនចៅញ៉ុមកើតនៅដំណាក់សង្កែរទាំងអស់!!អត់មានកើតនៅណាទេ!!

ក៖ ហ្ន៎អ៊ីចឹងអ្នកមីងកើតនៅស្រុកនេះទេអ៊ីចឹងហ្ន៎??

ខ៖ ហ្នឹងហើយ ហ្នឹង!!

ក៖នៅខេត្តកណ្តាល!

ខ៖ហ្នឹងហ្នឹង!!

ក៖ ភូមិដំណាក់សង្កែរ!!

ខ៖ចា៎!!

ក៖ ឃុំអីគេញ៉ុមអត់ដឹងដែរ តែដឹងតែថានៅកណ្តាលស្ទឹងដែរមីងហោ?

ខ៖ ហ្នឹងហើយ ខេត្តកណ្តាលស្ទឹង!!

ក៖ ស្រុកកណ្តាលស្ទឹង!!

ខ៖ចា៎!!

ក៖ចា៎!!ខេត្តកណ្តាលគេឥឡូវគេកាត់ចូលមកតាខ្មៅដែរ ដល់តែទៅណោះវិញបានកណ្តាលស្ទឹងមីងណោះ?

ខ៖ ហ្នឹងហើយ!!

ក៖ ដោយសារមីងប្រាប់មិញថានេះគេកាត់ចូលតាខ្មៅអស់ហើយ!!

ខ៖ ហ្នឹងគេថាមុនគេថាដំណាក់សង្កែរគេថាឃុំព្រែកកំពឹសខេត្តកណ្តាលស្ទឹង!

ក៖ចាំហ្នឹងហើយញ៉ុមដឹងហើយថាពេលមុនគេដាក់អីគេ !!

ខ៖ចាំ!!

ក៖ ភូមិដំណាក់សង្កែរ ភូមិព្រែកកំពឹង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

ខ៖ ចាំចាំ ហ្នឹងហើយ។

ក៖ ហ្នឹងអាពេលមីងកើតហាំ!!

ខ៖ ចាំចាំ ហ្នឹងហើយហ្នឹង!!

ក៖អ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមបងប្អូន៥នាក់ស្រី៣ប្រុសពីរ។

ក៖ ចាំ!!ឥឡូវគាត់ទៅណាស់អស់ហើយ?

ខ៖ នៅជុំគ្នាទាំងអស់អត់មានយកទៅណាទេ!!

ក៖ គាត់ក៏អត់មានស្លាប់ណាហី?

ខ៖ចាំអត់មានទេ!!

ក៖ចាំ!!

ខ៖ នេះបងញ៉ុមជាប់គ្នានេះ បងញ៉ុមនៅជាប់គ្នា២ នៅភូមិដំណាក់សង្កែមួយបងញ៉ុមបន្ទាប់ទីពីរ ទីពីរ ទីបីនៅហ្នឹងដែរ ទីបួនញ៉ុម!!

ក៖ចាំ!!

ខ៖ ហើយទីប្រាំងាប់បាត់ហើយពៅបន្ទាប់ញ៉ុមពៅគេ!!

ក៖ ចឹបានគាត់ស្លាប់?

ខ៖ ងាប់បាត់ហើយងាប់ប៉ុន្មានឆ្នាំហើយនេះផ្ទះគេជាប់ហ្នឹង!!

ក៖ និយាយថាថីបានគាត់ស្លាប់?ឈឺឬក៏អី?

ខ៖ ហ្នវាឈឺអូនអើយវាពេគច្រើនណាស់គ្រាន់តែស្អីថ្លើមផង ស្អីផង ថាមើលអស់លុយច្រើនណាស់!!មើលអស់ច្រើនណាស់!!

ក៖គាត់ហូបស្រាឬក៏អី?

ខ៖ ចាំ!

ក៖ស្រីឬក៏ប្រុសស្លាប់ហ្នឹង?

ខ៖ ប្រុស!! ប្រុសពៅគេបន្ទាប់ញ៉ុម!!

ក៖ ផឹក ជំងឺថ្លើម?

ខ៖ចាំ!!

ក៖ ផឹកភាគច្រើនជំងឺថ្លើម!!ចាំ!!

ខ៖ ហើយដល់ពេលហើយទៅមុជទឹកទៅរកត្រីរកអីអញ្ចឹងទៅណាស់ ដល់ហើយមើលអស់ច្រើនណាស់ ដល់ហើយពេគអីមើលអស់ច្រើនណាស់ ដល់ពេលវាស្លាប់ទៅវាខៀវខ្លួន
ខៀវដៃខៀវជើងអស់រលីងស្លាប់ទៅ!!ហើយដល់ពេលស្លាប់កូននៅអារញ៉ុង
កូន៣នាក់នៅអោយទាំងអស់ដល់ពេលឪស្លាប់បានប្រហែលជាប៉ុន្មានឆ្នាំបានកកូនការអស់រលីង !!

ក៖ហ្នំ!!

ខ៖ ឥឡូវកូនការអស់រលីងកូន!!

ក៖ហ្នំ!!

ខះចាំអានិតកូនប្អូនញុំមណាស់ថាពេលឪវានៅអត់ទាន់ការកូនណា
អត់ទាន់បានការកូនណាអីមួយទាល់តែឪស្លាប់ការអស់រលីង!!អីចឹងបានថាហ្នឹងហាំ!!
ដល់ពេលឥលូវម្នាក់កូនមួយកូនពីរអស់គ្រប់គ្នាហើយ!!

កះ
ឥឡូវមីងឥឡូវប្រាប់មើលថាបងប្អូនមីងទាំងប្រាំនាក់ហ្នឹងពួកគាត់ឈ្មោះអីគេខ្លះបងគេរហូតដល់ពេលគេ?

ខះ ហើយសួរអញ្ចឹងចង់យកទៅណា?

កះ ហ្វូំគ្រាន់តែចង់ប្រាប់ប្រវត្តិអ្នកមីងថាបងប្អូនមានឈ្មោះអីគេខ្លះអីចឹងណាស់!!

ខះ ហ្នឹងហើយ!!

កះ
ញុំមមានយកទៅណាណាញុំមគ្រាន់តែប្រាប់ពីប្រវត្តិរបស់អ្នកមីងនឹងហោ!!ឥលូវមីងចង់ប្រាប់ទេឈ្មោះ?មើលឥឡូវបងគេឈ្មោះអីគេដែរ?

ខះបងគេឈ្មោះអាត។

កះ បងបន្ទាប់ទៀត?

ខះ បងបន្ទាប់ទៀតឈ្មោះអាង។

កះ អាត អាង មួយទៀត?

ខះ ឈ្មោះរ៉ុ។

កះ ហើយមួយទៀត?

ខះ ញុំមឈ្មោះរី។

កះ មីង ឈ្មោះរី ហើយមួយទៀត ពូមួយដែលស្លាប់ហ្វូ?

ខះ ឈ្មោះអូន។

កៈ ចាំប៉ុន្តែត្រកូលដាក់ឆេងទាំងអស់ឬមួយដាក់ស៊ឹម?

ខៈ ដាក់ឆេង ឆេង។

កៈ ឆេងទាំងអស់ណោះមីងណោះ?

ខៈ ចាំចាំ!!មានតែប្រុសបងមួយគេបន្ទាប់ប្រុសបងដាក់ឈ្មោះស៊ឹមទេ!!

កៈ ចាំ!!

ខៈ គាត់ដាក់ឈ្មោះស៊ឹម !! ស៊ឹម សំអាង។

កៈ ចាំហ្អ៎ តែមួយហ្នឹងទេ?

ខៈតែមួយហ្នឹងទេ។

កៈ ចាំក្រៅពីហ្នឹងត្រកូលឆេងទាំងអស់ណោះមីងណោះ?

ខៈ ហ្នឹងហើយ រាល់ថ្ងៃកូនគាត់ការអស់ហើយនៅតែមួយបងទេ បងញ៉ុមគេការកូនស្រីពីរប្រុសពីរ ការពីរនាក់នៅបងគេមួយទៀតអត់ទាន់ការទេ ការប្អូនៗនៅបងគេអត់ទាន់ការទេ។

កៈ អញ្ចឹងមីងពួកគាត់រាល់ថ្ងៃពួកគាត់រកស៊ីអីគេដែរមីង?

ខៈ ប្តីញ៉ុមហេ?

កៈនិយាយថាបងប្អូនរបស់មីងគាត់រកស៊ីអីគេចិញ្ចឹមជីវិតដែរ?

ខៈ គេគេអ្នកធ្វើមេជាងផ្ទះគេផ្ទះ បងញ៉ុមគាត់ធ្វើមេជាងអាងហ្នឹងគាត់ធ្វើមេជាងហើយបងញ៉ុមមួយទៀតគាត់នៅផ្ទះមើលចៅ។

កៈហ្អ៎!!

ខៈ មើលចៅមើលអីកូនគេធ្វើការរោងចក្រហើយគាត់មើលចៅហ្នឹង។

កៈហ្អ៎ហើយមានអ្នកណាគេទៀតធ្វើការអីគេទៀតអីទេ?

ខះដឹងធ្វើការ បើប្តីញ៉ុមធ្វើការដែរធ្វើមេជាងដែរមេការហ្នឹងហិកាលមុនធ្វើនៅព្រៃករទាំងហ្នឹងហិផ្ទះគេ១០០ខ្នង!!!

កះ
ចាំអ្នកមីងពេលនៅក្មេងហាំអ្នកមីងធ្លាប់លេងអីគេខ្លះជាមួយបងប្អូនអ្នកមីងអ្នកមីងធ្លាប់លេងអីគេជាមួយគាត់ខ្លះ?
ហើយស្រលាញ់បងប្អូនត្រង់ចំនុចកន្លែងណាខ្លាំងជាងគេទៅ?អនុស្សាវរីយ៍នៅពីក្មេងដែរមីងធ្លាប់នៅជាមួយគាត់អ៊ីចឹងទៅណាស់ថាធ្លាប់ទៅបេះនេះទៅបេះនោះថាធ្លាប់ញុំាបាយអីជាមួយគ្នា មើលមីងប្រាប់បន្តិចមើលម៉េចដែរពេលនៅក្មេងជាមួយគាត់? ស្រណោះមែន?

ខះ មើលកូនញ៉ុមមួយនេះលក់ចាន ឆ្នាំង លក់ចានឆ្នាំង!!

កះអត់ទេនិយាយពីបងប្អូនរបស់មីងហាំ?

ខះ ចាំ??

កះ
បងប្អូនរបស់មីងពេលនៅពីក្មេងមកពួកគាត់នៅហ្នឹងមីងរស់នៅជាមួយពួកគាត់ពីក្មេងមែនទេ?

ខះ មួយណា?

កះអើរបងប្អូន ពូអាងពូអីហ្នឹងហាំ??

ខះឈ្មោះអូនហ្នឹងហោ?

កះហ្នឹងហើយ មីងធ្លាប់លេងអីគេខ្លះជាមួយពួកគាត់នៅពីក្មេងហ្ន៎!!

ខះវានៅកាលនេះវាមានអីវារត់តែម៉ូតូឌុបទេកាលវានៅរស់វារត់ម៉ូតូឌុបហាំ!!

កះ គាត់ប្រកបមុខរបរ។

ខះ ហើយប្រពន្ធគេនៅធ្វើការរោងចក្រហាំដល់ពេលហើយរោងចក្រគេហ្នឹងគេសារេរីឈប់អស់ទៅគេគេអោយមើលវាឈប់នៅផ្ទះមើលហ្ន៎!!ឈប់នៅផ្ទះទៅឥឡូវគេនៅរកស៊ីខាងរបស់របរអីគេទៀតគេនៅមើលថៅអីគេគេហ្នឹង!!ចាំ!!

ក៖ ចុះពេលនៅពីក្មេងឡើយពួកគាត់ទៅរៀនជាមួយមីងដែរតើមីង?ពេលក្មេងហាំ ពេលមីងនៅទូចៗហ្ន៎??

ខ៖ នៅទូចៗមានទាន់ធ្វើអីនៅរៀនចាំ!!

ក៖ នៅរៀនដើរទៅរៀនជាមួយបងប្អូនអីចឹងទៅ!!

ខ៖ ចាំ ដើរទៅរៀនដល់ពេលមានប្តីមានប្រពន្ធបានវាចេញមុខរកស៊ីអញ្ចឹងណាស់ ចាំ!!

ក៖ហ្ន៎!!

ខ៖ ពេលមានប្តីមានប្រពន្ធបានចេញមុខរកស៊ី ពេលនៅរៀនអត់ទាន់រកស៊ី អត់ទាន់រកស៊ីអីទេដល់ពេលមានប្រពន្ធមានអីបានចេញរកស៊ីអញ្ចឹងទៅ មុខការអញ្ចឹងអាមួយស្លាប់ទៅហ្នឹងរត់តែម៉ូតូឌុបទេ!!តែពីរជើង ពីរជើងទេ ហើយដល់ពេលរួចមកផ្ទះហើយ រត់ដឹកម៉ូយហាំ!!រត់ពីរជើងបាន១០០០០០ ២០០០០០បានអញ្ចឹងហាំ ពេលហ្នឹងវារត់បានថ្លៃណាស់រត់ម៉ូតូឌុបហារត់តែពីរជើងពីរជើងទេ ដឹកសាច់ជ្រូក ដល់ឥឡូវវាស្លាប់បាត់ហើយអាមួយហ្នឹងហ្ន៎!!ក៖ហ៊ឺ!!ខ៖ ដល់ឥឡូវគេនៅប្រពន្ធ ប្រពន្ធកូនចៅគេហ្នឹងហាំ!!គេថាធ្វើការខាងរោងចក្រហើយមួយទៀតគេលក់ចាប់ហ៊ួយនៅមុខ ហ្នឹង នៅមុខនេះ នេះផ្ទះនេះផ្ទះមានឡានហ្នឹងផ្ទះបងញ៉ុមហាំ !!

ក៖ចាំ!!

ខ៖ ផ្ទះមានឡានហ្នឹងហាំ!!អាជិះមកមិញហ្នឹងមុខផ្ទះមានឡានហ្នឹងហ្នឹងមុខផ្ទះបងញ៉ុម!!ផ្ទះបងញ៉ុមហើយបន្ទាប់មកទៀតផ្ទះបងញ៉ុមទៀត ចាំ!!

ក៖មីងធ្លាប់ទៅរកក្តាមរកខ្យងអីនៅពេលក្មេងៗអីជាមួយពួកគាត់ទេ?ធ្លាប់ទេ ពីនៅពីក្មេងទូចៗពេលទៅធ្វើស្រែអីហ្ន៎??

ខ៖ ញ៉ុមអ់តធ្លាប់ទេកូនខ្ញុំមួយនៅរៀនរាល់ថ្ងៃ១៣ឆ្នាំ ឆ្នាំហ្នឹងចូល១៣ឆ្នាំចូលរៀនទៅរៀនបាត់ហើយ!!

ក៖ចាំ!!

ខះទឹមតែចូលទេ ទឹមតែចូលឆ្នាំហ្នឹងទេ គ្រាន់តែចូលឆ្នាំហ្នឹងអស់ច្រើនណាស់វាចូលធំហើយ កាលពេលវានៅទូចៗពេលវាប្រហែលជា៣ ៤ ៥ខែញ៉ុមចេះតែយកទៅតាមរហូតដល់រតនៈញ៉ុមទឹមតែមកនៅតើ ញ៉ុមនៅឆ្ងាយៗណាស់ទៅតាមប្តីញ៉ុមទៅទន្លេអីចឹងទៅ នៅតាមអើរធ្វើម្ហូបកន្លែងបារាំងអញ្ចឹងទៅ នៅស្អីណាណោះហ្នូហូរហែរច្រើនណាស់ញ៉ុមទៅញ៉ុមទឹមតែមក ទឹមតែមកប្រហែលជា១ឆ្នាំជាងទេនេះ!!ញ៉ុមទឹមតែមកតើ!!

កះ អាហ្នឹងពេលមីងពេលមុន!!

ខះ បានយកទៅតាមអាហ្នឹងនៅជាប់ញ៉ុមមួយហើយផ្ញើរគេផ្ញើរឯងណាយកផ្ញើរគេផ្ញើរឯងមិនកើតទេយកទៅតាមមកនៅហ្នឹងបាននៅស៊ប់បានចូលថ្នាក់ចូលសាលាចូលសាលាឆ្នាំហ្នឹងហិហើយ អស់ច្រើនទៀតប៉ុណ្ណាណីចូលថ្នាក់ទីមួយហ្នឹង!!តែរៀនចេះ!!

កះតែអត់អអីទេ ហើយមីងពេលនៅពីក្មេងហាំមានដែលធ្លាប់រាវក្តាមរាវខ្យងឬក៏ធ្វើស្រែអីគេទេ?ខះចាំ!!កះ ពីក្មេងមកហ្នំពេលមីងនៅទូចហាំ ពេលមីងនៅទូចៗមានធ្លាប់ធ្វើការនៅស្រែនៅអីអីអត់?

ខះ ញ៉ុមអត់ទេ ញ៉ុមកាលនៅទូចៗបងញ៉ុមធ្វើស្រែកាលហ្នឹងសម័យហ្នឹងមានស្រែណាស់!!កះហ៊ឺ!!ខះ ហើយបងឯងធ្វើធ្វើស្រែ ធ្វើស្រែដែរ ធ្វើស្រែអីចឹងទៅញ៉ុមធ្លាប់ធ្វើស្រែអញ្ចឹងដែរញ៉ុមអត់ចេះទេទៅតាមបងញ៉ុមទៅចេះមើលគេច្រូតតិចទៅបាននៅចេះមើលអាចមើលគេច្រូតបានចងកណ្តាប់ចេះដកស្ទូងបានញ៉ុមធ្វើដែរតែធ្វើបានតែប៉ុន្មានឆ្នាំទេតែដល់ពេលញ៉ុមទៅភ្នំពេញម៉ែញ៉ុមតាមប្តីគាត់ធ្វើទាហានហ្នំតាមម៉ែគាត់ទៅនៅភ្នំពេញទៅនៅទួលគោកនេះ!!បានទៅទាំងអស់គ្នាចោលដីស្រែហ្នឹង កាលមុនគេចែកតាមក្រុមគេធ្វើរួមដល់ពេលហើយចែកតាមក្រុមញ៉ុមហើយនឹសងគ្រួសារញ៉ុម គ្រួសារម៉ែញ៉ុមហ្នឹងអត់មានបានដីទេព្រោះញ៉ុមទៅណោះអស់ទៅកូនគាត់ទៅតាមម៉ែគាត់អស់ទៅគេចែកដីតាមគ្រួសារហាំ អត់បាន អត់មានបានធ្វើអីណានៅរកស៊ីគេ គេធ្វើស្រែទៅគេមានស្រែធ្វើគ្រប់គ្នាទៅ ចាំ!!

កះតែពីក្មេងមកមីងគក៏ធ្លាប់ធ្វើដែរស្រែ!!

ខ៖ចាំ!!

ក៖ឃាយ ម៉ែរបស់មីងគាត់ធ្លាប់មានស្រែមានអីអ្នកមីងណោះ?

ខ៖
ចាំកាលមុនមានស្រែបានធ្វើរួមមានស្រែដល់ពេលគាត់ទៅធ្វើនៅភ្នំពេញគាត់ថាទុកចោលកូនហ្នឹងអត់បានគាត់ទៅតាមប្តីគាត់ថាទុកចោលកូនអត់បានទៅយកកូនទៅភ្នំពេញទាំងអស់យកកូនទៅនៅភ្នំពេញទាំងអស់ហ្នឹងទៅ!! ដល់ពេលសារើរហ្នឹតងដល់ពេលគេចូលទឹកអីហើយ គេសារើចែកគ្នាវិញហាំចែកតាមគ្រួសារវិញហាំ!!ចែកតាមគ្រួសារឯងអត់បានបណ្តោយម៉ងទៅ!!ឯងអត់បានទៅឯងអត់នៅហ្នឹងហាំ!!ចាំអត់នៅឯងនៅភ្នំពេញឯណោះ!!

ក៖ ហើយចុះគេអត់ផ្តល់ដំណឹងទេអីចឹង?

ខ៖ ចាំ!

ក៖ គេអត់ផ្តល់ដំណឹងអោយអ្នកមីងបានមកយកវិញ?

ខ៖អត់មានអត់ដឹង យើងអត់ដឹងសារើចែកតាមក្រុមតាមគ្រួសារវិញទេយើងមិនដឹងហើយដល់ពេលគេចែកអស់ម៉ងបានយើងមកម៉េចបាន
អាហ្នឹងគេចែកអស់ហើយយើងម៉េចបាន !!

ក៖ អាហ្នឹងពេលគេបែកប៉ុល ពតមកបានគេចែកហី!!

ខ៖ ចាំ ធ្វើ ធ្វើអត់បានរហូតទាល់តែឥឡូវហ្នឹងមានបាន មានបានធ្វើស្រែអីណាដល់តែឥលូវបានតែទិញអង្ករគេហូបហ្នឹង អញ្ចឹងមួយបេ មួយបេទៅណាស់!!

ក៖ ហ៊ី!! រាល់ថ្ងៃប្តីអ្នកគ្រប់គ្រងថ្លៃចាយវ៉ាយអីទាំងអស់ហ្នឹងអីចឹងទៅ!!

ខ៖ ចាំ!!

ក៖ អ្នកមីងម្តាយរបស់អ្នកមីងគាត់ឈ្មោះអីគេវិញ?

ខ៖ អីគេ?

ក៖ ម៉ែហាំ ម៉ែអ្នកមីង?

ខ៖ ម៉ែញ៉ុមហេ?

ក៖ ចាំ!!

ខ៖ ម៉ែញ៉ុមឈ្មោះអឿន។

ក៖ លោកយាយអឿន?

ខ៖ យាយទៀតហេ យាយម្ដាយគាត់ញ៉ុមអត់ស្គាល់គាត់ស្លាប់តាំងពីជំនាន់ញ៉ុមនៅទូចៗណោះ!!

ក៖ ចាំអត់អីទេ តែដឹងតែម្ដាយមីងគាត់ឈ្មោះអឿនហើយណោះមីងណោះ?

ខ៖ ចាំ ម៉ែញ៉ុមហ្នឹងបានឈ្មោះអឿនហើយពេលម្ដាយគាត់ទៀតញ៉ុមអត់សូវស្គាល់។

ក៖ ចាំត្រកូលយាយអឿនទេ?គាត់ឈ្មោះអីគេអឿន?

ខ៖ចាំ?

ក៖ ម៉ែហាំត្រកូលគាត់ឈ្មោះអីគេ?

ខ៖ ឪគាត់ឈ្មោះស៊ឹមហ្នឹង!!

ក៖ ចាំដឹងហើយ ប៉ុន្តែត្រកូលរបស់ម៉ែគាត់ឈ្មោះអីគេអឿន?

ខ៖ត្រកូលគាត់ទៀតហេ ត្រកូលគាត់ទៀតឈ្មោះអីគេទេនេះឈ្មោះអីទៀតក៏ញ៉ុមអត់សូវចាំដែរ!!

ក៖ ហ៊ុំអត់អីទេបើអត់សូវចាំក៏អត់អីដែរ!!តែម្ដាយរបស់អ្នកមីងឥឡូវគាត់ស្លាប់ហើយ?

ខ៖ ចាំ?

ក៖ គាត់ស្លាប់ហើយម្ដាយហេ?

ខ៖
ម៉ែញ៉ុមស្លាប់យូរហើយស្លាប់ប៉ុន្មានឆ្នាំហើយ!!ម៉ែញ៉ុមមើលប្ដីញ៉ុមស្លាប់បានប៉ុន្មានឆ្នាំបានម៉ែញ៉ុមស្លាប់បានម៉ែញ៉ូមស្លាប់។

ក៖ហ្ហ៎!!

ខ៖ ស្លាប់នៅហ្នឹងនៅហ្នឹងហ៎!!

ក៖ អ៊ីចឹង !! នៅផ្ទះហ្នឹង?

ខ៖ មិនមែននៅហ្នឹងទេ នៅណោះផ្ទះណោះ!!មិនមែននៅហ្នឹងឧទាហរណ៍ថានៅស្រុកហ្នឹង!!

ក៖ចាំចាំ!!

ខ៖ ប៉ុន្តែស្លាប់នៅផ្ទះញ៉ុមណោះទេ!!

ក៖ ប៉ុន្មានឆ្នាំហើយយាយស្លាប់?

ខ៖ ស្លាប់យូរដែរហើយអូនណ្ហើយញ៉ុមអត់ចាំទេ ប្ដីញ៉ុមស្លាប់ប្រហែលចង់២ឆ្នាំ៣ឆ្នាំហើយបានម៉ែញ៉ុមស្លាប់ដែរ!!បានម៉ែញ៉ូមស្លាប់ បានម៉ែញ៉ុមស្លាប់បានប៉ុន្មានឆ្នាំបានប្អូណញ៉ុមអាពៅស្លាប់ដែរ!!!

ក៖ អ៊ីចឹងមិនមែន២ ៣ឆ្នាំទេអ៊ីចឹងយូរហើយមីងហោ?

ខ៖ ចាំ ញ៉ុមអត់ចាំដល់តែសួរបងញ៉ុមនេះ បងញ៉ុមប៉ុនកត់ណាស់!!គ្រាន់តែញ៉ុមចេញដំនើរថ្ងៃណា គាត់កត់ហើយបានប៉ុន្មានខែប៉ុន្មានខែគាត់កត់ហើយ ថ្ងៃណាមកវិញប៉ុន្មានខែគាត់កត់បងញ៉ុមនេះគាត់ចេះអក្សរបងញ៉ុមនៅជាប់នេះ!!

ក៖ ពូកែចំណាំ!!

ខ៖បងញ៉ុមហាំលក់ចាប់ហ្វ៊ុយ!!

ក៖ចាំ!!

ខ៖ លក់ចាប់ហ្វយផ្ទះគេមានតសំយ៉ាប់ហ្នឹងហាំ!!គាត់ប៉ុន!!

ក៖ហ៊ឹ!!

ខ៖ មានតែគាត់មួយទេគាត់បងបង្អស់ !!

ក៖ គាត់ចំណាប់អារឿងថ្ងៃខែ!!ហ្នឹងម៉ងមីងហោ?

ខ៖ ចាំ ហ្វាំចាំណាស់!! អ្នកណាសួរគាត់អស់អាចមន៍អស់នោមគាត់ចាំទាំងអស់!!ហើយគាត់ថាមិនមែនចាំតែកូនចៅគាត់ គាត់ចំាទាំងបងប្អូនឯងហ្នឹងហាំ!!

ក៖ចាំ!!

ខ៖ គាត់ចំាទាំងអស់ !!

ក៖ ញ៉ុមចង់សំភាសន៍គាត់ដែរមីងហិ!!

ខ៖ បងប្អូនចេញដំនើរទៅណាគាត់កត់ទាំងអស់!!គាត់កត់ភ្លាមញ៉ុមទៅប៉ុន្មានខែគាត់កត់ដែរ!!ញ៉ុមមកវិញបានប៉ុន្មានថ្ងៃបានប៉ុន្មានខែគាត់កត់ទៀត។

ក៖គាត់ថាណោះង៉ែងចេញទៅថ្ងៃណាថ្ងៃណាអញកត់ទាំងអស់ហិ ង៉ែងចេញទៅបានប៉ុន្មានខែបានប៉ុន្មានខែអញកត់ទាំងអស់ហិ គាត់អ៊ីចឹងហិ មានតែគាត់ទេបងប្អូនញ៉ុម បើញ៉ុមអត់វីរវល់ បងញ៉ុមមួយទៀតអត់វីរវល់បងញ៉ុមបងបន្ទាប់មួយទៀត អត់វីរវល់ដែរ!! ហើយវីរវល់តែគាត់មួយចាំថ្ងៃណាទៅថ្ងៃណាកត់ទុកអីអត់ទេ!!

ក៖ចាំ!!

ខ៖ ដូចថាកើតណោះ ពោះធំឆ្លងទន្លេកើតថ្ងៃនេះ កើតថ្ងៃនេះកើតខែណាឆ្នាំណាប៉ុន្មានពាន់ណាគាត់កត់ ញ៉ុមអញ្ចឹងដែរមិនដែលរវល់កត់ណា!!

ក៖ អត់ដឹងហោ?

ខ៖ ញ៉ុមអញ្ចឹងដែរ មានតែគាត់តែម្តង!!!

កះ ហ៊ីៗ!!គាត់កត់ចំណាំ!!

ខះ គាត់កត់អក្សរគាត់ចំណាប់ម៉ងអូនហា!!

កះចា៎!!

ខះ  គាត់កត់ទុក  បើយើងចង់ចំណាំសារេរីយើងចង់ធ្វើអីធ្វើអីអញ្ចឹងទៅធ្វើកំណើតយើងហើយសួរយើងកើតខែណាឆ្នាំណាកើតប៉ុន្មានពាន់អ៊ីចឹងទៅអីអញ្ចឹងៗទៅណាស់ ហើយដល់ពេលយើងអត់សួរអត់កត់អ៊ីចឹង យើងសួរអត់ដឹងងុងអីគេទេ!!ដូចញ៉ុមអញ្ចឹងហ៎!!

កះ អត់អីទេមីងបើយើងអត់សូវចាំអ៊ីចឹងហើយណោះ!!

ខះចា៎!!

កះអ៊ីចឹងអ្នកមីងសំរាប់ឆ្នាំខ្មែររបស់ម្តាយអ្នកមីងគាត់កើតឆ្នាំអីអ្នកមីងចំាទេ?អត់ដែរហើអី?

ខះ ចាំមើលសួរគាត់!!

កះបងបានចាំអញ្ចឹងហេ?

ខះ ចា៎!!ហ្នឹងហើយ!!

កះ ចា៎ អូខេឈប់សិន ម្តាយអ្នកមីងស្លាប់យូរណាហើយតែអត់ចាំឆ្នាំដែរមីងណោះ?

ខះ ហ៊ីស្លាប់យូរណាស់ហើយអត់ចាំទេ មានតែគាត់ចង់សួរចង់ដឹង បើសួរចំគាត់បានសួរដឹងម៉ង បើសួរចំញ៉ុម!!

កះចា៎!!

ខះ អត់ដឹងងុងអីគេទេ!!

កះចា៎!!

ខះហ៊ី!!

កៈអ៊ីចឹងអ្នកមីងសំរាប់ម្តាយរបស់អ្នកមីងគាត់ស្លាប់ដោយសារមូលហេតុអីគេដែរ?គាត់ចាស់ឬក៏គាត់មានជំងឺ?

ខៈគាត់ចាស់ដែរហើយ!! មុនហ៎អូនណាស់ម៉ែញ៉ុមគាត់កាន់សីល សីល១០ហ៎គាត់កាន់សីល១០ហ៎!! ទៅវត្តទៅវ៉ា កូនព្រលឹមឡើងជូនលុយអញ្ចឹងហិ!! តែកូនចៅស្រមោចវាលើអីអញ្ចឹងគាត់អត់អោយឯងធ្វើបាបអីគេទេ គាត់អត់អោយធ្វើបាបទេ គាត់អោយផ្លុំចោល!!ហើយគាត់ចាំ ហើយគាត់កាន់សីលណាស់!!ហើយបើថាកូនចៅណាដែរ មិនថាកូនចៅខ្លួនគាត់ទេ គាត់ចៅណាអត់ស្គាល់ក៏ដោយ កូនចៅគាត់មើលគេអត់ស្គាល់អោយតែយំតាមម៉ែឪ ម៉ែឪទៅដល់ណាអ៊ីចឹងយំតាមផ្លូវគាត់ឃើញគាត់ហៅអោយយកលុយហើយ!!អោយលុយអញ្ចឹង២០០ ៣០០ ៥០០អីអញ្ចឹងទៅ!! ដូចថាអញ្ចឹងមានលុយចូលបុណ្យ អញ្ចឹងញ៉ុមធ្វើបុណ្យដែរតើ តែញ៉ុមធ្វើបុណ្យដោយមុខ បើអ្នកមីងញ៉ុមធ្វើបុណ្យ ធ្វើអាលែមអាលើមអាលែមអាលើម ញ៉ុមថាញ៉ុមចាំអោយហ្វ៎!!មើលទៅស្លូតបូត មើលទៅមានចិត្តថ្លើមអីចង់ចូលជាមួយបុណ្យហ្នឹងហ៎ញ៉ុមចូលអោយទៅ ៥០០អីអញ្ចឹងទៅមានអីទៅ មាន៥០០ ចូល៥០០មាន២០០ ៣០០ចូល២០០ ៣០០ទៅ អត់មានទៅស្រសេស្រសៃ !!

កៈ ហ្នឹងហើយ!!

ខៈ ថាញ៉ុមទៅវត្តអីទៅផ្សារអ៊ីចឹងហិ អាឡែងឡើងលើឡៅអញ្ចឹងហិ គេចុះទៅឡើងទៅសុំទានសងខាងមកវិញសុំទានសងខាង ថ្ងៃណាអត់មានលុយរាយអត់ទៅថ្ងៃណាមានលុយរាយអញ្ចឹង ២០០ ៣០០ ៥០០អ៊ីចឹងទៅអូនណាស់!!

កៈចាំ!!

ខៈ
ហើយបើចុះមកអញ្ចឹងអត់មានលុយរាយមានតែលុយដុំញ៉ុមអត់អោយដែរ!!ហើយបើថាអ្នកសុំទានអី មកដូចថាក្រលែមក្រលើមអីមកថាធ្វើគរបើថាញ៉ុមអោយទៅ ញ៉ុមប្រាប់!!កៈចាំ!!ខៈហ្នឹង!!

កៈ និយាយទៅយើងត្រូវអោយហ្នឹងដាក់ទានហ្នឹងមើលមនុស្សដែរ!!

ខ៖ចាំ!!

ក៖រកអ្នកណាដែលអត់មានបានធ្វើអីបានហ្នឹងបានយើងគួរអោយ!!

ខ៖ ចាំហ្នឹងហើយ!!

ក៖បានអោយគាត់ដោយសារគាត់អត់មានធ្វើបាន!!

ខ៖ អញ្ចឹងបានថាគួរមានចិត្តមាននិស្ស័យជាមួយអ្នកសុំទានហ្នឹងដាក់អោយអញ្ចឹងដាក់អោយ៥០០ ១០០០អញ្ចឹងញ៉ុមអត់ស្តាយទេ!!បើថាអ្នកសុំទានធ្វើក្រលែមក្រលើមធ្វើអីជេរអីហ្នឹងញ៉ុមអត់រវីរវល់ទេ!!!

ក៖ចាំ!!

ខ៖ អញ្ចឹងបានញ៉ុមថា!!

ក៖ អញ្ចឹងម្តាយអ្នកមីងគាត់ស្លូតបូតអ្នកមីងណោះ?គាត់មុននឹងស្លាប់គាត់កាន់សីល១០?អញ្ចឹងស្លូតបូតខ្លាំងណាស់ ចិត្តធម៌ខ្លាំងណាស់!!

ខ៖ សីល១០មិនបាច់ទេ!! ហើយកូនចៅគាត់ហាំ អោយតែម៉ែញ៉ុមអោយបាយអោយបាយហាំញ៉ុមប្រាប់អូនឯងបានគាត់ដាំគាត់ថាហ៊ី គាត់ចាំហូបបាយជាមួយកូនដល់ពេលកូនទាល់តែម៉ោង៨ ម៉ោង៩បានគាត់ដាំបានគេដាំបានដាក់បាយអត់ទាន់បាតលោកហាំ លោកតែម៉ោង៧ ម៉ោង៨ ៨ជាង៩ហ្នឹងលោកបិនហើយហើយកូនចៅហូបជាមួយកូនចៅម៉ោងជិត៨ ជិត៩បានដាំហើយម៉េចទាន់ បានស្លអីគេទាន់ ចាំ ហើយគាត់ដាំខ្លួនគាត់ ចង្ក្រានហ្គាសគាត់មានឆ្នាំងបាយ ឆ្នាំងសម្លរគាត់មានចានបាយចានសម្លរគាត់មានគាត់ដាំផ្សេងហើយគាត់តែម៉ោង៧ជាង៨ហ្នឹងគាត់ដាំហើយហើយគាត់ដួសបាយដាក់មួយចានដាក់សម្លរមួយចានបាយមួយចានដាក់ចង្ហាន់លោកលោលបិនអញ្ចឹងទៅគាត់ដាក់បាតលោកអញ្ចឹងទៅ ហើយដល់ពេលកូនចៅណាគេមានយំតាមអញ្ចឹងទៅ យំគាត់ហុចលុយអោយគេឃើញម៉ែញ៉ុមហុចលុយអោយគេហើយបងញ៉ុមហ្នឹងហាំ!!ថាអញ្ចេកមិនដឹងជាស្អីទេម៉ែគ្រាន់តែ

កូនគេអោយដែរ!! ហ៊ីកូនអោយទៅកូនគេកូនឯងចៅគេចៅឯងកូនឯងកុំចេះថាអញ្ចឹងម៉ែធ្វើបុណ្យកូនណាស់!!

កះចាំ!!

ខះ ធ្វើបុណ្យធ្វើបុណ្យមិនដែលស្គាល់កូនអាណាគេផងអញ្ចឹងហាំ!!

កះ ហ្នឹងហើយ តាមពិតលោកយាយគាត់ចិត្តល្អធ្វើបុណ្យអត់រើសមុខអ្នកមីងហាំ!!

ខះ ហ្នឹងហើយគាត់ធ្វើបុណ្យខ្លួនគាត់!!

កះ ចាំល្អណាស់អ៊ីចឹង!!

ខះ ហើយដល់ពេលកូនគាត់បងគាត់ចេះតែថាអញ្ចេះថាអញ្ចះកូនឯងម៉ែធ្វើបុណ្យកូនណាស់មិនចាំបាច់ថាចៅឯងកូនឯងទេ!!កូនគេអីក៏ដោយអោយតែយំម៉ែអាណិតម៉ែអោយហើយ!!ជួនកាលឃើញដើរអញ្ចឹងដើរដំណើររកម៉ែឪមិនឃើញម៉ែគាត់អោយហើយ!! ម៉ែហៅអញ្ចឹងស៊ីបាយអញ្ចឹងទៅ!!ចាំហើយអ្នកសុំទានដើរអញ្ចឹងហាមីអូនណាស់ហើយម៉ែកំពុងពិសារបាយ
ហើយបាយតែមួយចានហ្នឹងហាគាត់សុខចិត្តមួយចានគាត់ដួសដាក់ចង្ហាន់លោកហើយបានមួយចានហើយសល់មួយចានមានដល់អ្នកសុំទានដើរអញ្ចឹងគាត់សុខចិត្តហៅមកហូបបាយហ្នឹងគាត់សុខចិត្តអត់ហូបមាត់គាត់ណាស់!!

កះ ហ៊ីល្អម្ល៉េះ !!

ខះ ចាំអ៊ីចឹងក៏មានដែរហាំ!!ចាំហ្នឹងហើយ ដល់ពេលហើយហើយអ៊ីចឹងបងហាំមីអូនណាស់មកហូបបាយហាំ មកអញ្ចឹងទៅគាត់សុខចិត្តគាត់អត់ហូបបាយខ្លួនគាត់គាត់សុខចិត្តអោយអ្នកសុំទានមានបានហូប!!

កះចាំ!!

ខះអញ្ចឹងហាំ!!ឃើញគាត់មិនបាច់ទេម៉ែញ៉ុម!!បានថាម៉ែញ៉ុមស្លាប់គាត់ស្លាប់ចាស់!!

កះចាំ!

ខ៖
អញ្ចេកកុំអីគាត់អស់ស្លាប់ទេអញ្ចេកគាត់ឆ្លោះចង្កេះហើយគាត់ថាគាត់ដើរអត់បានគាត់ទាស់ទាស់នេះដល់ហើយយកអោយគ្រូគេតប់ គ្រូគេតប់គ្រូហ្នឹងថាមើលហើយបងខឹងតប់ៗគាត់អូនហើយតប់គាត់តប់មិនមែនចាប់សរសៃចាប់អីណាលែងយកឬស្សីប៉ុនករដៃដំបងហ្នឹង!!ក៖ចំ!!

ខ៖ យកទៅវ៉ៃៗវ៉ៃដំបងហាំ!!ចាំ!វ៉ៃចង្កេះគាត់ហ្នឹងហិទៅពីរដងឡើងហើមប៉ុននេះទៅហើយគាត់ហើមយើងមើលយកគាត់ទៅគាត់ឡើងដំបៅ អូនអើយញ៉ុមថាស្មាទោសដំបៅប៉ុណ្ណឹងគាត់អត់មានប្រាប់កូនចៅអីណាទេ ហើយគាត់ដើរលែងរួចហើយ ដើរលែងរួចហើយ លែងរួចគាត់នៅតែរំកិលមួយកន្លែងអញ្ចឹង ផ្លាស់សារ៉ុងគាត់ទៅបត់ជើងផ្លាស់សារ៉ុងអញ្ចឹងទៅ គាត់នោមក៏ផ្លាស់សារ៉ុងគាត់ដល់ពេលថ្ងៃមួយគាត់ចង់ទៅមែនទែនគាត់រំកិលៗកូនចេះតែទាញអញ្ចឹង អាកូនចៅឯងអត់ដឹងទាញអញ្ចឹងឡើងរបូតដល់ពេលមើលជើងដំបៅហាដល់ពេលមើលទៅឃើញសារ៉ុងគាត់ឃើញស្នាមរបកៗឃើញនៅភ្លៅគាត់ប៉ុណ្ណាណរីឃើញឡើងក្រហូរៗៗឡើងប៉ុណ្ណឹងហិ!!

ក៖ គាត់អត់ព្រមប្រាប់មីងណោះ?

ខ៖ ហ្នឹងហើយអត់បានប្រាប់ទេ!!

ក៖អោយបានព្យាបាលទាន់!!

ខ៖ គាត់ថាខ្លាចកូនចៅមើលទៅប៉ះពាល់របស់គាត់ខ្លាចប៉ះដំបៅគាត់ខ្លាចបាបអីអញ្ចឹងណាស់!!

ក៖ហ្ហ៎!!

ខ៖ បានសុខចិត្តគាត់បានថាអត់ថ្មឹងហ្នឹងហាំខ្លួនគាត់ឈឺខ្លួនគាត់អញ្ចឹងហិ!!

ក៖អូយឈឺខ្លាំងណាស់មីងអើយ!!

ខ៖ អញ្ចឹងបានថាគាត់សាហាវណាស់ម៉ែញ៉ុមហាំ!!

ក៖ហ៊ីទ្រាំនោះទ្រាំ!!

ខ៖អត់ប្រាប់កូនចៅថាកូនម៉ែដំបៅនេះម៉ែគេវ៉ៃថប់ម៉ែហើយឥឡូវម៉ែដំបៅ!
គាត់អត់មានប្រាប់អីបន្តិចសោះ!!
ទាល់តែខ្លួនគាត់ស្លាប់ទាល់តែគេបង្វិលអញ្ចេកបានដឹងថាគាត់ឃើញមានដំបៅឡើងប៉ុណ្ណឹងហា!!

ក៖ចំមីងអើយមីង!!

ខ៖ហ្នឹងហើយមីអូនឯងមើលអញ្ចឹងហា!!

ក៖អានិតគាត់ណាស់!!

ខ៖ គាត់អត់ប្រាប់កូនចៅទេ!!គាត់អត់ប្រាប់ទេគាត់ថាខ្លាចកូនចៅខ្ពើមចាំគាត់ប្រាប់ថាខ្លាចកូនចៅខ្ពើមទៅឃើញថាលាបថ្នាំលាបអីទៅពោយអោយទៅខ្លាចខ្ពើមដល់ហើយគាត់អត់ប្រាប់ទេ គាត់ទុកខ្លួនគាត់ហ្នឹងឈឺថ្ងៃណាស្លាប់ថ្ងៃណាចាំទៅដល់ពេលគាត់ស្លាប់ទៅបានដឹងតើ បានកូនចៅដឹងគ្រប់គ្នា!!បានបងញ៉ុមថាអញ្ចេកម៉ាអាគ្រូត្រូវគ្រាប់ថាយកទៅអោយចាប់សរសៃមិនចាប់ទៅយកដំបងវ៉ៃអញ្ចឹងណាស់ ដេរហើយថាបងញ៉ុមបងញ៉ុមនេះ
បងញ៉ុមព្រែកហូរនេះថាបងឯងទៅខឹងគេអីបើយើងរកគេគេមិនមករកយើងឯណាហ្នឹងហើយបើគាត់និយាយអីចឹងត្រូវអត់?

ក៖ ចាំម្យ៉ាងដែរ!!

ខ៖យើងទៅរកគេ!!

ក៖ចាំ!!

ខ៖ ហើយគេមិនមែនមករកយើងទេ យើងទៅរកគេអោយគេមើលចាប់អើរបើយើងទៅរកគេបើយើងមិនទៅរកចាប់សរសៃមិនទៅរកចាប់សរសៃម៉េចទៅយកដំបងវ៉ៃយកដំបងវ៉ៃយកឫស្សីវ៉ៃអោយឡើងដំបៅឡើងអញ្ចឹង!!

ក៖ចាំ!!

ខ៖ហើយបងប្អូនញ៉ុមថាអញ្ចឹងហើយមួយៗថាមិនបាច់ទេ!! បានថាបងមួយទៀតនិយាយអញ្ចេក អើរមិនបាននិយាយទេបើបានគាត់ស្លាប់ហើយ បានគាត់ស្លាប់ហើយបានឃើញនាំគ្នានិយាយ ដល់ពេលគាត់នៅរស់អត់មានអ្នកណាគេនិយាយ!! ចុះបើអ្នកណាគេដឹង អត់អ្នកណាគេដឹង ចាំបើអត់មានអ្នកណាគេដឹង!!

ក៖ចាំ!!គាត់លាក់!!

ខ៖ ហើយញ៉ុមហាំ ញ៉ុមបំរើគាត់សព្វគ្រប់អស់ហើយ ចុះឥលូវនៅបងៗ ហើយបងនៅតាវែសនៅភូមិដំណាក់សង្កែមួយ ហើយញ៉ុមនៅជាប់គ្នាអញ្ចឹងហិ នៅបំរើគាត់នោមអញ្ចឹងផ្លាស់សារ៉ុងយកទៅគក់បោកសាប៊ូអីហាលផ្លាស់សារ៉ុងមួយទៀត ហើយគាត់មាឧធំណាស់អូន អូនអើយមាឧធំណាស់!!

ក៖ហ្ហ៎!!

ខ៖ លើកគាត់៣ ៤នាក់លើកមិនចង់រួច ហើយគាត់ហើម ហើយលើកគាត់ស្លៀកទំរាំបានឈរបានអីទៀតយូរណាស់ ហើយណាហត់មែនទែន!!

ក៖ហ៊ឺ!!

ខ៖ ហើយដល់ពេលញ៉ុមទាល់ច្រកខ្លួនញ៉ុម ញ៉ុមអត់មានប្តីប្តីញ៉ុមស្លាប់បាត់ទាល់តែទឹមតែបានប្តីក្រោយរាល់ថ្ងៃនេះញ៉ុមប្រាប់អូនឯងតាមត្រង់!!

ក៖ចាំ!!

ខ៖ ប្តីញ៉ុមក្រោយ ហើយដល់ប្តីញ៉ុមស្លាប់ ញ៉ុមថាញ៉ុមសល់តែកូន កូនចៅអស់ហើយនៅតែមីមួយពៅគេហ្នឹងញ៉ុមថាហ៊ឺអញនៅតែម្នាក់ឯងអញ្ចឹងរកទៅ គេនៅរតនៈគិរីគេជិះឡានមកគេមករកកម្មករ កាត់ផ្កាកៅស៊ូ!!

ក៖ហ្ហ៎!!

ខ៖ អញ្ចឹងហាំ កាត់ផ្កាកៅស៊ូហើយនឹងជំរះស្មៅ ដល់ហើយមករក មករកចំផ្ទះញ៉ុមហ្នឹងហិ ចំផ្ទះញ៉ុម ជិះឡានមកទៅ គេមេការហាំ ដល់ហើយគេសួរថាមានស្រីណាទេ មានស្រីៗទំនេរអត់ រកហៅទៅធ្វើការកៅស៊ូ កាត់ផ្កាកៅស៊ូហើយនឹងជំរះស្មៅ ជំរះស្មៅកៅស៊ូហ្នឹង!!ដល់ហើយញ៉ុមស្មគ្រ័ចិត្តទៅហើយណាស់ហើយឪម៉ែញ៉ុមកំពុងតែឈឺហើយណាស់ គាត់កំពុងឈឺដែរ!!

ក៖ហ្ហំ!!

ខ៖ញ៉ុមថាទៅទៅ ញ៉ុអាងបងញ៉ុមនៅជិតហ្នឹងដែរ!!

ក៖ចាំ!!

ខ៖ ហើយប្អូនញ៉ុមអាមួយពៅពេលហ្នឹងវាអត់ទាន់ស្លាប់វាថាអញ្ចេក ហ៊ីមិនបាច់ឃាត់ទេ ត្រូវរៀបចំដាក់ឥវ៉ាន់ដាក់ខោអាវហើយ ឃាត់បងមួយឃាត់ បងមួយទៀតឃាត់ បងមួយទៀតឃាត់អាប្អូនមួយទៀតឃាត់ដែរ
ថាអញ្ចេកអើយមិនបាច់ឃាត់នឹងអាវីទេអាវីថាទៅវាទៅហើយ
អាវីវាជំនេះណាស់ថាទៅណាវាទៅហើយឆ្នាស់ចំម៉ាយហើយ ថាអោយញ៉ុមអញ្ចឹងហាំ ឆ្នាស់ចំម៉ាយហើយកាចណាស់!! បើថាវាចង់ទៅណាហើយទៅហើយមិនបាច់ឃាត់វាទេ មិនបាច់ឃាត់ឃាំងទេ អោយវាទៅអស់តែមួយខ្យល់ទៅ ហ្នឹងអញ្ចឹងហាំអាមួយពៅថាងាប់ទៅហ្នឹងហាំ!!

ក៖ចាំ!!

ខ៖
ញ៉ុមទៅអស់មួយខ្យល់ញ៉ុមដំនើរទៅហើយបានក្មួយញ៉ុមមួយទៀតថាអញ្ចេកហ៊ីមិនបាច់ឃាត់គាត់ទេបើឃាត់គាត់មីង មីងឯងទៅធ្វើអី បើមីងឯងអត់ស៊ីមានស៊ីអីញ៉ុមមិនមែនមើលមីងឯងមិនឃើញដែរញ៉ុមមិនហុចអោយ!!
ហ៊ីចុះក្មួយអើយក្មួយ
មីងអត់ស៊ីក្មួយឯងអោយមីងតែម្តងមួយយាមក្មួយឯងម៉េចអោយមីងរាល់ថ្ងៃ!!

ក៖ ហ្នឹងហើយ!!

ខ៖ មីងចង់ទៅធ្វើការធ្វើងារអីចឹងបានលុយមកដាក់ហោរប៉ៅហ្នឹងខ្លួនឯងចង់អីអញ្ចឹងហាមានស៊ីអីទិញខ្លួនឯងចង់អីទិញស៊ីខ្លួនឯងចុះបើមីងអត់ទៅរកអីអញ្ចឹងអាបាយសំលរអាម្ហូបម្ហាគេអោយតែម្ដងមួយយាមទេ!!ណាស់!! ជឿអត់អូន!!

ក៖ចាំចាំ!!

ខ៖ ហើយដល់ពេលយើងរកអញ្ចឹងទៅបានលុយបានកាក់មកអញ្ចឹងខ្លួនឯងចង់ទិញខោអាវទិញអីទិញអីអញ្ចឹងទិញចានឆ្នាំងទិញអីទៅចង់ហូបអីហូបអីមានលុយខ្លួនឯងហើយចុះបើយើងឃ្លានបានលុយឯណាទិញស៊ីយហ៊ានសុំគេហ៎??ហ្នឹងហើយយើងនិយាយជឿអត់?

ក៖ ចាំចាំ!!

ខ៖ ទោះបីកូនក៏មិនហ៊ានហាមាត់សុំកូនសុំទិញស៊ីដែរ!!

ក៖ ត្រូវមីងត្រូវ!!

ខ៖ហ្នឹងហើយ ហើយកូនបើថាម្ដាយឃ្លានហើយយូរៗអោយម្ដងមួយយាមចុះបើគេចិញ្ចឹមកូនគេដែរ ហ្ន៎ហ្នឹងហើយ!!

ក៖ ហ្នឹងហើយនិយាយអីចឹងត្រូវមីង!!

ខ៖ អញ្ចឹងបានត្រូវហា៎ អញ្ចឹងបានជំនះទៅខ្លួនឯងហា៎ទៅទៅទៅរហូតដល់ណាដល់ណីអត់ស្គាល់ទេទៅបានតែពីរថ្ងៃអានេះអានេះពួកម៉ាក់ញ៉ូមហិបានគេថាហ៊ីអាវីទឹមតែទៅធ្វើការបានប៉ុន្មានថ្ងៃស្គាល់គេស្គាល់ឯង អញនៅបានប៉ុន្មានឆ្នាំអត់មានស្គាល់អាណា!! ចុះបើគេបានសំដីអញ្ចឹងបាននិយាយចេះនិយាយចុះនិយាយអញ្ចឹង រាប់អានថាស្រលាញ់ញ៉ុមគ្រាន់តែថាស្រលាញ់មិនមែនចាត់ទុកធ្វើជាប្រពន្ធហា៎!!គ្រាន់តែស្រលាញ់រាប់អានថាចាត់ទុកញ៉ុមជាប្អូនរបស់គាត់អញ្ចឹងណាស់!!

ក៖ចាំ!!

ខ៖មេការហ្នឹងហាំ!!ហើយថា

ក៖អ្នកមីងរួសរាយ!!ហ្នឹងហើយ។

ខ៖ ចាំអញ្ចឹងបានគេថាទឹមតែមក ទឹមតែមកស្គាល់មិនបានកន្លះខែផង ស្គាល់គេស្គាល់ឯងឯងនៅរាប់ឆ្នាំឯងមិនទាន់ស្គាល់អាណា!!អើរមកពីមិនបានមាត់មិនបានក៏អាហ្នឹងមកពីយើងទេ ចេះបើអូនជឿអត់!!

ក៖ជឿ!!

ខ៖ ញ៉ុមបានមាត់បានករ ញ៉ុមពូនិយាយពាក្យនេះនិយាយអញ្ចេះនិយាយចុះ ហើយបើយើងនៅរាប់ឆ្នាំយើងមិនដែលនិយាយរកអាណាមិនបាន!!

ក៖ ម៉េចស្គាល់!!

ខ៖ ចាំអញ្ចឹងបានតែថាហ្នឹងហាំ!!

ក៖ហ្នឹងហើយ!!

ខ៖ បានស្គាល់អាណា!!

ក៖ហើយញ៉ុមទៅញ៉ុមស្គាល់ញ៉ុមទៅធ្វើការអញ្ចឹងហៅអានេះហៅអានោះហ្ហំមានអីគេហូប ហៅគេហៅឯងទៅ ហើយបើយើងមានអីហូបស៊ីតែឯងមានស្គាល់អាណា!!

ក៖ ត្រូវមីងត្រូវ!!

ខ៖ហ្នឹងហើយ!!

ក៖
អ៊ីចឹងមីងសំរាប់ម្ដាយរបស់អ្នកមីងពេលគាត់នៅពីអើរពេលមីងនៅទូចៗហាំគាត់រកស៊ីអីគេដែរ ចិញ្ចឹមមីង ធ្វើស្រែឬក៏មានអីគេធ្វើទៀតទេ?

ខ៖ ចុះបើញ៉ុមអត់ ញ៉ុមរាល់ថ្ងៃ!!

ក៖អត់ទេអត់ទេ ម្ដាយមីងហាំ??

ខ៖ ហ្នំ!!

ក៖ ម្ដាយរបស់អ្នកមីងដែលស្លាប់ទៅពេលមីងនៅកូនក្មេងនៅប៉ុនៗញ៉ុមនេះហា!!

ខ៖ចាំ!!

ក៖ ពេលនៅប៉ុនញ៉ុមនេះហា!!

ខ៖ អត់ទេកូនញ៉ុមធំៗ ធំៗហើយ!!

ក៖អត់ទេអ្នកមីង
ពេលអ្នកមីងនៅក្មេងៗម្ដាយរបស់អ្នកមីងគាត់រកស៊ីអីគេដែរអោយមីងធំឡើងអញ្ចឹងណាស់?

ខ៖ ចាំ!!

ក៖ គាត់ធ្វើស្រែហើយគាត់មានធ្វើអីគេទៀតទេ?

ខ៖ អត់ អត់មានទៀតផង អត់មានចាប់អារម្មណ៍ទៀត តែពេលគាត់ឈឺអីចឹងទៅ កូនធំៗកូនរកស៊ីចិញ្ចឹមគាត់វិញទេនេះហា!!

ក៖ហ្អ!!

ខ៖ចាំចាំ!!

ក៖ អញ្ចឹងពេលមុនគាត់គ្រាន់តែរកស៊ីចិញ្ចឹមដើម្បីអោយរកស៊ីចិញ្ចឹមមីងអីវ៉ាន់ទេ រកស៊ីចិញ្ចឹមកូនៗគាត់ដូចពូអាន ពូអឿនអីវ៉ាន់ហ្នឹងហី?

ខ៖ចាំ!!

ក៖ហេមិនមែនពូអឿនទេ យាយអឿនម៉ែវិញហើយទេ!!អញ្ចឹងគាត់រកស៊ីធ្វើស្រែ!!

ខ៖ អញ្ចឹងពេលហ្នឹងឈ្មោះហ្នឹងកូនចិញ្ចឹមគាត់កាលគាត់លើកមុននៅ កាលកូនគាត់មិនទាន់ឈឺគាត់ធ្វើការធ្វើអីអញ្ចឹងទៅ កូនមានប្ដីមានប្រពន្ធអស់ហើយ កាលគាត់មិនទាន់ឈឺគាត់នៅក្មេងដែរ គាត់ទៅវត្តអញ្ចឹងទៅកូនទៅ កូនចៅដល់ពេលថ្ងៃសីលជូនគាត់ទៅម្នាក់១០០០០

ម្នាក់៥០០០អីអីចឹងទៅចា៎!!ហើយដល់ពេលកូនធំៗអស់ទៅហើយ ដល់ទៅគាត់ដល់ពេលគាត់ស្លាប់កូនធំៗអស់ហើយ!!កូនមានលុយហុចនេះហុចនោះអញ្ចឹងកូនធ្វើការអញ្ចឹងបើកលុយអោយគាត់ទៅ ២០០០០ ជូនកាលទៅ១០០០០អីចឹងទៅអាខ្លះគេអត់៥០០០អីចឹងទៅ!! ហ៊ីអញ្ចឹងគាត់សន្សំៗគាត់ទុកខ្លួនគាត់ដល់ថ្ងៃសីលគាត់ទិញម្ហូបទិញម្ហូបទៅវត្ត។

កះ ចា៎ហ្នឹងហើយ!!

ខះ ហ្នឹងហើយ!!

កះអីចឹងគ្រាន់តែធ្វើស្រែហើយនឹងធ្វើការអីបន្តិចបន្តួចហើយនឹងធ្វើការអីកូនចិញ្ចឹមពេលគាត់រៀងចំណាស់អីទៅដែរហើយអញ្ចឹង!!!!

ខះចា៎!!

កះ អញ្ចឹងឪពុកអ្នកមីងគាត់ឈ្មោះអីគេដែរឪពុក?ឪពុកមុនហា៎!!តាស៊ឹមហា៎មែនទេ?

ខះចា៎!!

កះអីគេស៊ឹម?ចាំត្រកូលគាត់ទេ?

ខះ ហ៊ី ស៊ឹម ស៊ឹម អឿន!!

កះអត់ទេអត់ទេ ប្រពន្ធឈ្មោះអឿន ឪពុកឈ្មោះស៊ឹម(ម្តាយគាត់ឈ្មោះអឿន ឪពុកគាត់ឈ្មោះស៊ឹម)?

ខះចា៎!!

កះ តតែអត់ចាំត្រកូលតាស៊ឹមទេហី ដូចមីងឆេង រី ដល់ពេលតាឈ្មោះស៊ឹមតែអីគេស៊ឹមហ្នឹង?

ខះ ចា៎!!ចាំមើលហាគាត់បានប្តីក្រោយឈ្មោះតាឆេងឆេងហ្នឹងប្រពន្ធគាត់ឈ្មោះស៊ឹមប្រពន្ធក្រោយប្រពន្ធគាត់ប្តីគាត់ហ្នឹងហាឈ្មោះស៊ឹម ដល់តែឥឡូវប្តីគាត់ហ្នឹងស្លាប់បាត់ហើយ ស្លាប់បាត់តែមានកូន កូនគាត់បីនាក់ស្រីៗ កូនស្រី៣នាក់ហ្នឹងហា៎ កូនចុងម៉ៃញ៉ុមហ្នឹងហា៎!!

កៈ ហ្ហ៎អីចឹងតាឆេងហ្នឹងនៅសល់ទៀត?

ខៈ កូនតាឆេងហ្នឹងហាំ ចាំ!!មានកូនស្រីពនាក់សព្វថ្ងៃហ្នឹងហិ ពនាក់មានប្រពន្ធមានប្ដីអស់ហើយ!!

កៈចាំ!!

ខៈមានប្ដីហើយអស់ហើយ។

កៈអីចឹងឪពុករបស់អ្នកមីងមិនមែនឈ្មោះតាឆេងទេ តាស៊ឹម តាឆេងហ្នឹងឪពុកក្រោយទេ?

ខៈចាំ!!ឪពុកក្រោយ!!

កៈអញ្ចឹងដោយសារតាស៊ឹមស្លាប់បានគាត់យកប្ដីមួយទៀត?

ខៈ ចាំ!!ហ្នឹងហើយបានពីជំនាន់អាពត។

កៈហ្ហ៎!!

ខៈ ហ្នឹងហើយបានពីជំនាន់អាពត តែគាត់បានកូនមួយដែរហាំ បានកូនមួយហ្នឹងបានតាឆេងហ្នឹងហាំ!!តែបានកូនដែរ តែពេលគាត់ទៅលើកទំនប់ លើកទំនប់ជីកទំនប់ជីកប្រឡាយតាមស្រុកយើងនេះហិ ទំនប់យើងសព្វថ្ងៃនេះហិ គាត់លើកទំនប់រែកដីរែកអីនេះហិមកបណ្ដោយទៅ អត់បានអត់មានអត់នៅទាល់តែរហូតទាល់តែគាត់ចាស់ងាប់ហ្នឹងហិ!!ចាំ!!

កៈ ហ្ហ៎អញ្ចឹងជាមួយតាឆេងអត់មានបានកូនអីមួយគ្រាប់ទេ!!

ខៈ ចាំហ្នឹងហើយ!!

កៈបានតែជាមួយតាស៊ឹម។

ខៈ បានតែមានតែអត់នៅ។

កៈ មីងចាំឪពុកមីងថាចីបានតាស៊ឹមស្លាប់អត់?ឪពុកមីងតាស៊ឹមហ្នឹងហាំចីបានស្លាប់?

ខ៖ មើលតាស៊ឹមហ្នឹងហា៎ កុំអីបានតែស្លាប់ហ្នឹងហោ អញ្ចេកកាលហ្នឹងនៅពីតូចៗញ៉ុមអត់សូវចាប់អារម្មណ៍គាត់ឈឺជំនាន់ហ្នឹងជំនាន់អាពតអាពតវ៉ែ។

ក៖ហ្ន៎អីចឹងអាពតសម្លាប់តាទេអីចឹង?

ខ៖ ចា៎!!អាពតវ៉ែ អញ្ចេកញ៉ុមដឹងដែរដឹងអាពតវ៉ែញ៉ុមដឹងខ្លះៗដែរហា៎!!

ក៖ចា៎!!

ខ៖ មីអូនហានៅទូចៗដឹងខ្លះដែរ!!យើងអញ្ចឹងផ្ទះអញ្ចឹងហា៎ ជញ្ជាំងៗជាប់ៗៗអញ្ចឹងហា៎ញ៉ុមថាដល់ពេលជំនាន់អាពតហ្នឹងគេហៅគាត់ទៅណាគាត់ទៅណាទេញ៉ុមភ្លេចទៅគេហៅគាត់មិនដឹងទៅណាទេដល់ពេលហើយចេញទៅចេញទៅផ្ទះមុខផ្ទះមានភក់។

ក៖ចា៎!!!

ខ៖មានភក់អាពតចេញមក!!

ក៖ហ៊ឺ!!

ខ៖ចេញមកគេសួររក សួរគាត់ថាអើយមានស្គាល់ប្រធានភូមិអត់?ហើយតែគាត់អត់ហ៊ានប្រាប់គាត់ថាទុកចិត្តខ្លួនគាត់ថាអត់ហ៊ានប្រាប់ហា៎គាត់ថាហ៊ឺញ៉ុមអត់ដែលស្គាល់ទេ ហ៊ឺនិយាយបានមួយម៉ាត់ពីរមួយម៉ាត់ពីរវាចាប់បានវាវ៉ៃ វាជាន់កប់ភក់ទៅ !!

ក៖ ហើយស្លាប់នៅហ្នឹងទៅ?

ខ៖ កប់ភក់ ដល់ពេលហើយអត់ទាន់ងាប់ទេណាស់ សម្លាប់គាត់អត់ទាន់ងាប់ទេ !!

ក៖ហ្ន៎!!

ខ៖ ដល់ពេលនៅផ្ទះបានប្រហែលប៉ុន្មានគាត់ស្លាប់ទៅគាត់ស្លាប់អញ្ចឹង!!

ក៖ហ្ន៎!!

ខ៖ចាំ!!

ក៖ វារ៉ៃខ្លាំងណាស់ដែរហ្នឹងមីង!!

ខ៖ចាំ!!

ក៖ ពួកអាហ្នឹងមានទៅថ្នមដៃអី!!

ខ៖ចាំ! ចាំរ៉ៃហើយហ្នឹងបានស្លាប់ហ្នឹង!ញ៉ុមដឹងដែរញ៉ុមដឹងពីអញ្ចឹង ដឹងខ្លះៗដែរ!!

ក៖ ហ្ហ៎អ៊ីចឹងបានយាយជួបតាឆេង ដូចថាប្តីស្លាប់ហើយតែគ្រាន់តែថាជួបតាឆេងនៅក្នុងជំនាន់ប៉ុល ពតទៀតទៅ?

ខ៖ ចាំ!!

ក៖ហ្ហ៎!!

ខ៖ ហើយដល់ពេលគាត់ស្លាប់បានពេលហើយទាល់តែជំនាន់អាពត គេបានលើកទំនប់លើកអីបានគាត់បានតាឆេងហ្នឹងក្រោយទៀត!!ក៖ចាំ!!ខ៖តាឆេងក្រោយហ្នឹង!!

ក៖ មីងស្រលាញ់ឪពុកតាស៊ឹមហ្នឹងអត់?មុននឹងគាត់ស្លាប់ហ្នឹងគាត់ជាមនុស្សល្អទេតាស៊ឹមហ្នឹង?

ខ៖ ហ៊ីគាត់មិនដឹងម៉េចផង សួរញ៉ុមញ៉ុមអត់សូវដឹងដែរ!!

ក៖ អត់ចាំទេហេ ?អត់ចាំក៏អត់អីដែរ!!ហើយពេលបានតាឆេងមក តាឆេងចិត្តល្អអ្នកមីងដែរតើហេ ឪពុកអ្នកមីងក្រោយ!!

ខ៖ គាត់ល្អ!! កូនចៅគាត់គាត់អត់សូវរវីរវល់ទេណាស់ មករវីរវល់កូនចៅញ៉ុមនេះ កូនចៅម៉ែញ៉ុមនេះទាំងអស់!!

ក៖ ដោយសារចិត្តបានទេហី?ដូចរបៀបថាចិត្តបានជាមួយគាត់បានគាត់រវល់ជាមួយច្រើន!!អញ្ចឹងមីងណោះ?

ខ៖ ចាំហ្នឹងហើយ!!

ក៖ដោយសារពួកគាត់ជាមនុស្សល្អ។

ខ៖ ពេលម៉ែ ពេលម៉ែញ៉ុមស្លាប់បាត់ហ្នឹង គាត់នៅវត្តនៅវត្ត នៅវត្តកាន់សីលនៅវត្តនៅវត្តបំរើលោកទៅ បំរើទឹកក្តៅទឹកអីអញ្ចឹងទៅណាស់!!ហើយព្រឹកឡើងម៉ោង៥គាត់ធាក់កង់ទៅផឹកកាហ្វេ ផឹកកាហ្វេផឹកអីនៅព្រែកហូរអ៊ីចឹងណាស់ ហើយគាំតមកវិញ គាត់រៀបចំដាំទឹកក្តៅហើយអញ្ចឹងពេលលគាត់មកវិញគាត់ងើបហើយគាត់ងើបដាំទឹកក្តៅទឹកអី អញ្ចឹងប្រគេនលោកប្រគេនអីហើយបានគាត់ដាក់ប៉ាន់លោកអញ្ចឹងបានគាត់ជិះកង់ទៅផឹកកាហ្វេ កាហ្វេគាត់ខ្វះអីគាត់អត់ផឹកគាត់ចង់ទៅផឹកកាហ្វេនៅផ្សារ!!

ក៖ ដើម្បីមានគ្នាមានអីព្រួកប្រាជ្ញអីអញ្ចឹងទៅណេះអ្នកមីងណេះ?

ខ៖ ហើយដល់ពេលគាត់មកវិញគាត់មកទៅ ដល់ពេលម៉ែញ៉ុមស្លាប់គាត់ហ្នឹងគាត់មកតែកូនចៅម៉ែខាងញ៉ុមទេ កូនចៅគាត់៣នាក់គាត់អត់មានរវីរវល់អីគេទេ!!ដល់ពេលយូរៗទៅដល់ពេលគេស្អីៗមានអីមាន អីបន្តិចបន្តួចគាត់យកមកណេះហើយ!!មកអោយកូនយកអោយបងញ៉ុមនេះ បងញ៉ុមបងគេបង្អស់នេះហ៎!!ក៖ចាំ!!ខ៖ ហើយដល់ហើយបងញ៉ុមយកមកចែកប្អូនចែកអីទាំងអស់ទៅ ដល់ពេលឥឡូវម៉ែញ៉ុមស្លាប់បានយូរៗទៅគាត់ទៅខាងកូនគេវិញទៅ ឥឡូវខាងកូនម៉ែញ៉ុមគាត់មិនសូវរវីរវល់ទេឥឡូវហ្នឹងហ្ន៎!!

ក៖ហ្ន៎!!

ខ៖ តែដល់ពេលថ្ងៃចូលឆ្នាំចូលខែ ញ៉ុមថ្ងៃចូលឆ្នាំហ្នឹងហ៎ភ្ជុំហ្នឹងហ៎ ញ៉ុមជូនគាត់១០០០០ ១០០០០អើរបងៗញ៉ុមទៀត ២០០០០ ២០០០០ ញ៉ុមអត់សូវមានលុយញ៉ុមជូនគាត់១០០០០ ១០០០០។

ក៖ ហ្នឹងតាមសទ្ធាយើងទៅមីងណោះ?

ខ៖ចាំ!!

កះអញ្ចឹងអ្នកមីងសំរាប់យាយ ជីដូនជីតាខាងមីងអ្នកមីងស្គាល់ទេយាយហាំ!!

ខះចាំ!!

កះ យាយរបស់មីងមីងស្គាល់ទេ?ខាងម៉ែ?

ខះ យាយខាងប្តីគាត់ហ្នឹង?យាយខាងឪពុកញុំមហេ?

កះទាំងខាងពុកទាំងខាងម៉ែមានស្គាល់អ្នកណាគេអត់?

ខះ ញុំមអត់ស្គាល់ ញុំមអត់ស្គាល់ទេ!!

កះ ហ្ហំ!!

ខះ ញុំមអត់សូវស្គាល់!!

កះ កើតមកអត់ទាន់តាទាន់យាយទេអញ្ចឹងហេ?

ខះ ញុំមស្គាល់តែយាយ តែយាយខាងម៉ែញុំមហ្នឹង!!យាយញុំម ញុំមអត់ស្គាល់ផង ញុំមស្គាល់តែមុខតែញុំមអត់ភ្លេចឈ្មោះ!!ភ្លេចឈ្មោះ!!

កះហ្ហំ!!

ខះភ្លេចឈ្មោះហើយ។

កះ ពេលហ្នឹងកើតមកទាន់គាត់នៅរស់ទៀត?

ខះ ចាំ!!

កះ មានដែលទៅលេងគាត់អីអត់?

ខះ ឥឡូវគាត់ស្លាប់ហើយញុំមប្រាប់យាយខាងម៉ែញុំមហ្នឹង !!

កះចាំ!!

ខះ ញុំមនៅតូចហ្នឹងគេចំបក់សង្គ្រាមហ្នឹងម៉ែញុំមគេនាំគ្នារត់នៅកន្លែងនេះនេះហិ នៅកន្លែងឡូតដ្ឋនេះ ឡូតដ្ឋញុំមនៅតូច ញុំមនៅតូចដែរទេ ញុំមនៅទូចណាស់

ហើយថាទឹមតែប៉ុន្មានឆ្នាំទេ តែគ្រាន់តែថាញ៉ុមចេះដឹងហាំ!!ដល់ហើយម៉ែញ៉ុមថាយាយញ៉ុមថាអញ្ចេកកូនៗ ប្រាប់ម៉ែញ៉ុមអញ្ចឹងកូនៗអោយហ្អែងអោយទៅជាមួយម៉ាក់អោយទៅជាមួយអញទៅអញគ្រាន់តែបំរើគ្រាន់បុកស្លាបុកអី ហើយម៉ែញ៉ុមថាហ៊ីយកអារីមួយយកទៅអញ្ចឹង ដល់ហើយញ៉ុមទៅ នៅវត្តតាំងរនាមនេះគេគៀរ ញ៉ុមនៅបានប្រហែលប៉ុន្មានទេប៉ុន្មានអាទិត្យគ្រាប់បាញ់សង្គ្រាមសង្គ្រាមទៀតរត់ហើយកូនធម៌គាត់ហ្នឹងហាំ កូនធម៌គាត់បងម៉ែកូនធម៌ម៉ែញ៉ុមហ្នឹងហាំទៅយកញ៉ុម ទៅយករហូតដល់វត្តតាំងរនាមហ្ហ៎!!ថាយាយយាយម៉ែអោយយកអារីទៅវិញ ថាអញ្ចឹងណាស់ថាម៉ែអោយយកអារីទៅវីញយាយម៉ែគាត់ហ្នឹងថាអញ្ចេកហ៊ីអោយអារីនៅជាមួយអញហើយយកវីញ ហ៊ីយកយកទៅអញកាត់កាលចោលហើយមិនថាជាជីដូនជីតាណាទេយាយតាយាយថៅណាទេបើថាអោយមកអញមួយហើយយកទៅវិញមួយយកទៅ!!

កៈយាយខាងម៉ែហ្នឹងហេ?

ខៈ
យាយខាងគាត់ហ្នឹងហាយាយខាងម៉ែគាត់ហ្នឹងហាំ!!ថាហ៊ីបានអោយមួយហើយបានតាមមកយកវិញហ៊ីឥឡូវយកទៅអញអត់គ្មានយាយដូនឯណាទេ!!យាយជីដូនយាយថៅណាទេកាត់កាលចោលហើយ អញ្ចឹងហិ បានប៉ុន្មានទេ បានញ៉ុមមកដល់ផ្ទះ ស្អែកឡើងឮថាគេគៀរគៀរគាត់ធ្លាក់ទៅក្រោមបាត់ទៅបាត់ស្រមោលគាត់ទៅ!!

កៈហ្ហ៎!!

ខៈចាំចាំបាត់ស្រមោលទៅ!!

កៈ ហ្ហ៎អញ្ចឹងយាយប្រហែលជាគាត់ស្លាប់!!

ខៈ
មិនដឹងនៅដល់ណាដល់ណី!!ពេលយើងនៅស្រុកស្រួលប្រួលយើងនៅតាមស្រុកតាមទេសដឹងអត់លឺសូរដំណឹងគាត់នៅឯណា។

កៈ ក៏បាត់គាត់ឈឹងអឺចឹងទៅ!!

ខៈ មានតែបាត់ មានតែងាប់បាត់ហើយ!!ពេលគេគៀរទៅហ្នឹង!!

កះ ចុះតាអីវ៉ាន់មានចាំអីគេទេ??តា?

ខះ តាខាងប្តីគាត់ហ្នឹងស្លាប់តាំងពីគាត់ពីគាត់នៅជំនាន់សង្គមហ្ន៎!!

កះហ្ន៎!!

ខះ ចា៎!!

កះ ហ្ន៎អញ្ចឹងពេលមុនសម័យសង្គ្រាមហ្នឹងទៀត!!

ខះ ចា៎ស្លាប់តាំងពីជំនាន់សង្គមហ្នឹងប្តីគាត់ហ្នឹង!ញ៉ុមចាំខ្លះដែរពេលញ៉ុមនៅទូចៗ!!

កះហ្នឹងហើយ!!

ខះ ញ៉ុមធ្លាប់នៅជាមួយគាត់អញ្ចឹងទៅ ដល់ពេលយូរៗញ៉ុមធ្លាប់ជាញ៉ុមនឹកឃើញគាត់ម្តងៗចេះតែនឹកឃើញចាំដែរ ដល់ពេលអញ្ចឹងញ៉ុមអត់ចាំទាំងអស់!!!

កះ ចា៎ហ្នឹងហើយ!!

ខះ ចា៎ញ៉ុមអត់ចាំទាំងអស់!!

កះ សូម្បីតែញ៉ុម!!

ខះចា៎!!

កះ ក៏អត់សូវចាំពីយាយតាញ៉ុមច្រើនប៉ុន្មានដែរ!!

ខះ ចា៎យើងនៅតូចៗដែរពេលជំនាន់អាពត ពេលជំនាន់សង្គមយើងនៅទូចៗដែរ !!

កះចា៎!!

ខះ ញ៉ុមចាំដែរហ្នឹង!!ចាំខ្លះៗតែអត់ចាំទាំងអស់!!

កះចា៎!

ខ៖ ដល់ពេលបែកទៅមិនដឹងទៅណាមកណាហើយដល់ពេលសារ‌រើពេលគេស្រុកស្រួលប្រួលទៅនៅតាម ដល់ពេលហើយទៅរកនៅតាមវត្តិគោករនាម ហា់គោករមៀតនេះហិ ហើយបានគេថាហើយគេបានសារ‌រើថាសុខស្រួលប្រួលវិញហើយ ទៅនៅតាមស្រុកតាមទេសវិញទៅ ណានៅភូមិណា ណានៅភូមិណានៅវិញទៅបានមកភូមិឯងវិញហិ!!

ក៖ ចា៎!!

ខ៖ ចា៎បានមករត់មកនៅភូមិខ្លួនឯងវិញនៅភូមិជំណាក់សង្កែទើរតែឥឡូវហ្នឹងហិ!!

ក៖ ក៏ត្រលប់មកនេះវិញអញ្ចឹងទៅ!!ខ៖ហ៊ឺ!!ក៖ ហើយចុះមីងបងប្អូនមីងមានដែលមានអ្នកណាគេធ្លាប់ទៅរស់នៅប្រទេសខាងក្រៅអីឬក៏ទៅធ្វើការនៅក្រៅប្រទេសក្រៅពីស្រុកខ្មែរយើងហ្នឹងទេ?មានដែលទៅធ្វើការនៅថៃមានដែលទៅធ្វើការនៅស្រុកក្រៅអីណាអត់?

ខ៖ អត់ អត់មានដែលដើរទៅណាមកណា ដល់ពេលចេញពីហ្នឹងមក មកនៅហ្នឹងជាប់រហូត!!

ក៖ បងប្អូនអត់មានអ្នកណាទៅណាណាហោ?

ខ៖ ចា៎នៅហ្នឹង!!

ក៖ នៅជុំគ្នា?

ខ៖ នៅជុំគ្នាហ្នឹងម៉ងអត់មានទៅណាមកណា អត់មានបងប្អូនណានៅឆ្ងាយទេ។

ក៖ចា៎!!

ខ៖ ដល់តែឥឡូវហ្នឹងមានដែលនៅឆ្ងាយមានតែកូនចៅញ៉ុមអាមួយនៅយ៉ុងវ៉ាអាមួយទៀតនៅស្អីគេនេះកំពង់ចាម!!

ក៖ចា៎!!

ខ៖កំពង់ចាមញ៉ុមហ្នឹងនេះ!!

កៈចាំ!

ខៈ នៅឥឡូវនៅសព្វថ្ងៃហ្នឹងហិ!!

កៈ ចាំឆ្ងាយដែរ!!

ខៈ ដល់កូនម៉ែញ៉ុមអត់មានអ្នកណានៅឆ្ងាយនៅជុំគ្នា ជុំគ្នាហ្នឹងគ្រាន់តែថារំលងផ្ទះមួយពីរដល់ រំលងផ្ទះមួយពីរដល់ !!

កៈហ៊ិ!!

ខៈ ចាំនៅជុំគ្នាអញ្ចឹង!!ហ៊ឺ!!

កៈអូខេ!!

ខៈ ប៉ុន្តែឥឡូវអូនអើយយើងអស់ណាស់ រាល់ថ្ងៃជួលផ្ទះគេ ផ្ទះញ៉ុមអូនឯងចាំមើលផ្ទះនោះ ផ្ទះញ៉ុមសព្វថ្ងៃហ្នឹងហាំបាក់ ព្រោះអញ្ចេកគេចាក់ផ្លូវហាំគេអោយខិតចុះខិតឡើងបងញ៉ុម បងញ៉ុមហាំ បងខ្ញុំហ្នឹងអោយខិតចុះខិតឡើង ប៉ាងសុីរ៉ូសចុះរ៉ូសឡើងរ៉ូសតែពីក្រោយដល់ពេលគេអោយរូសមកមុខរូសមកមុខ គ្រាន់តែរ៉ូស៣សារ ហើយប៉ាងសុីគ្រាន់តែស្នាមក្បាលដែកគោល ប្រហោង ប្រហោងក្បាលដែកគោល ចុះប៉ាងសុីគាស់ចុះគាស់ឡើងមិនប្រហោងក្បាលដែកគោល!!

កៈចាំ!!

ខៈ ដល់ហើយជាប់ហ្នឹង ដល់តែឥឡូវបាក់បែកអូនឯងមើលពីមុនទៅធ្លុះធ្លាយដល់ក្រោយហ្ន៎!!

កៈអាផ្ទះនេះហ្នឹងមែនហិ?

ខៈ ហ្នឹងគេហ្នឹងមិនដឹងនៅណាទេ ផ្ទះ!!

កៈហ្ន៎!!

ខៈ ផ្ទះហ្នឹងកាលមុនគេនៅហ្នឹងហាំញ៉ុមនៅណោះផ្ទះហ្នឹងគេចងករងាប់!!

កៈអូ!!

ខះប្តីផឹកណាស់ ប្តីផឹកហើយចេះហើយប្រពន្ធធ្វើក្រចកដៃក្រចកជើងប្រពន្ធ ប្រពន្ធធ្វើក្រចកដៃក្រចកជើងហើយកូនប៉ុន្មានទេ ខ្មៅ ប្រពន្ធហ្នឹងឈ្មោះមីខ្មៅ!!រាល់ថ្ងៃវាផឹកស៊ីវាផឹកស៊ីអញ្ចឹងៗ ហើយដល់ហើយវាដូចម៉េចវាចងករ វាចងករងាប់ ខាងនេះគេចងករងាប់ដែរនេះញ៉ុមនៅប្រលោះគេនេះហ៎!!

កះ ហ៊ីអានិតណាស់!!

ខះ អាផ្ទះគេនេះនោះ!!អាផ្ទះហ្នឹងចងដែរ ចងករងាប់ដែរ!កះចាំ!!ខះមានប្រពន្ធកូន៣កូន៤ហើយ។

កះអញ្ចឹងសងខាង អ្នកជិតខាងមីងពេលមុនសុទ្ធតែអ្នកចងករស្លាប់មីងណោះ?

ខះ តែស្លាប់អស់យូរហើយ ស្លាប់មិនដឹងទៅចាប់ជាតិទៅនៅណាទៅនៅណីអីអស់ហើយ វាអត់ឥឡូវញ៉ុមអត់ ញ៉ូមអត់ខ្លាចទេ ញ៉ុមងើបម៉ោង៤ញ៉ុមងើបងើបដើរទៅផ្ទះកូន មកវិញនៅផ្ទះកូន មកវិញបោសដីបោសអីបបរអោយគេហូបអញ្ចឹងព្រលឹមឡើងគេទៅធ្វើការ ម៉ោង៤ងើប ម៉ោង៤ងើបហើយអត់ខ្លាចទេ!! ម៉ោង៤ងើបបើបត់ជើងញ៉ុមបើភ្លើងបំភ្លឺបង្គន់។

កះចាំ!!

ខះដល់ពេលចូលមកបិត
បិតទ្វារម៉ោង៤ងើបដើរទៅញ៉ុមអត់ដែលចេះខ្លាចអីគេទេ!!ព្រោះចងករមិនមែនទឹមតែឥឡូវត ល្ងវណាប៉ុន្មានឆ្នាំប៉ុន្មានវាងាប់និស្ស័យអស់ហើយ!!

កះហ្នឹងហើយវាសាបវារលៀបលែងមានខ្មោចលងទៀតហើយហោ?

ខះចាំ!!វាអស់ជាតិអស់ចូរអីហើយវាចាប់ជាតិទៅណាទៅនៅណីអស់ហើយ!!

កះ ចាំហ្នឹងហើយ!!

ខះ គ្រាន់តែសងខាងហ្នឹង សងខាងហ្នឹងសុទ្ធតែចងករ!!ផ្ទះហ្នឹងគេរ៉ុសអស់ចោល ប្រពន្ធគេទៅនៅផ្ទះខាងម៉ែគេនៅព្រៃកហូរហ្នំ!! ហើយផ្ទះនេះមិនដឹងនៅណា បាត់ស្រមោលមិនដឹងទៅឯណាទេ!!

កះចាំ!

ខ៖តែនេះពាងរបស់គាត់ពាងម្ចាស់ផ្ទះហ្នឹងគេអោយប្រើបងគេអោយប្រើ ប្រើទៅនៅតែផ្ទះហ្នឹងស្អាមគេគាស់អីអស់ហើយប្រហោងផ្លុងហ្នឹងហ្ន៎!!

ក៖ចាំ!!

ខ៖ ញ៉ុមអត់ខ្លាចទេ ញ៉ុមនៅម្នាក់ឯងម៉ោង៩ញ៉ុមចេញទៅក្រៅហើយ អាខ្លះឃើញអញ្ចឹងគេអត់ខ្លាចគេឃើញស្រមោល ឃើញមនុស្សអត់ឃើញខ្មោចតែឃើញផ្ទះគេខ្លាចហាំ!!

ក៖ហ្នឹងហើយ !!

ខ៖ ប៉ុន្តែញ៉ុមអត់ខ្លាចម៉ង!!ប៉ុនពេលដែលប្តីញ៉ុមស្លាប់ហាំ ស្លាប់យប់ហ្នឹងហាំ បងញ៉ុមទិញប៊ីយ៉ែរប៉ុន្មានកេសប៉ុន្មានកានអោយផឹកស៊ីទៅដល់៣ ៤ ៥ថ្ងៃហ្ន៎!!ហើយហើយអោយយាមអោយកំដរញ៉ុមខ្លាចថាញ៉ុមខ្លាច ហើយបងញ៉ុមសួរថាអញ្ចេកឥឡូវអារីឯងខ្លាចអត់?ញ៉ុមថាអត់ខ្លាចទេ !! អញ្ចឹងអត់ខ្លាចអញអោយគេទៅផ្ទះហើយ គ្រាន់តែកំដរគេប៉ុន្មានថ្ងៃអស់ស្រាឡើងប៉ុន្មានកានហើយ។

ក៖ ចាំអញ្ចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងក៏ដូចជាបងប្អូនដូនតាអញ្ចឹងណាស់អ្នកមីង!!

ខ៖ ចាំចាំ!!

ក៖ ចាំអរគុណ។